

តើអ្វីជា
"កិច្ចតែងការបង្រៀនអំពីបរិស្ថាន
ដែលប្រើប្រាស់គម្រោង
រឿងដំណាលអំពីមនុស្ស"?

# រឿងនិទាន
# និងធនធានធម្មជាតិ
# នៅជុំវិញយើង

តើអ្វីជា
"កិច្ចតែងការបង្រៀនអំពីបរិស្ថាន
ដែលប្រើប្រាស់គម្រោង
រឿងដំណាលអំពីមនុស្ស"?

# រឿងនិទាន
# និងធនធានធម្មជាតិ
# នៅជុំវិញយើង

# តារាងមាតិកា


- សេចក្តីផ្តើម ៣
- រឿងទីទុយនិង ក្តាន់ (The Owl and the Deer) ៥
- ប្រវត្តិស្រុក កែវ សីមា (History of Keo Seima District) ១៥
- រឿង ផាដែង និង ព្រះនាងអាយ (Pha-Daeng and Nang Ai) ២១
- សារជូនចំពោះអ្នកសម្របសម្រួល៖ គោលបំណងនៃសម្ភារៈឧបទ្ទេស និងរបៀបប្រើប្រាស់សម្ភារៈទាំងនេះ ៣១






# សេចក្តីផ្តើម

*ជីវិតរបស់យើងត្រូវបានទទួល* ដោយធនធានធម្មជាតិ ដែលរស់នៅតាមដងទន្លេ និងនៅក្នុងព្រៃ។ មានរឿងព្រេង និងរឿងនិទានជាច្រើន ដែលយកធម្មជាតិមកធ្វើជាប្រធានបទសំខាន់ ហើយបានបន្សល់ទុករហូតដល់សព្វថ្ងៃនេះ។ ប៉ុន្តែដោយសារនាពេលបច្ចុប្បន្ន ប្រជាជនដែលនៅរស់មានចំនួនច្រើនជាងមុន ស្របពេលជាមួយនឹងការរីកចម្រើនផ្នែកអភិវឌ្ឍសេដ្ឋកិច្ចផងដែរនោះ ការបំផ្លិចបំផ្លាញធម្មជាតិនៅតាមដងទន្លេ និងនៅក្នុងព្រៃក៏បានកើតឡើងផងដែរ។ ជាមួយគ្នានេះដែរ នៅពេលដែលយើងកាន់តែចូលចិត្តប្រើប្រាស់ ទូរទស្សន៍ ទូរស័ព្ទដៃ និងឧបករណ៍ទំនាក់ទំនងផ្សេងៗទៀត ឱកាសក្នុងការស្តាប់រឿងនិទាន ដែលដំណាលពីជំនាន់ជីដូនជីតារបស់យើង និងជីតាជីដូនលួត និងជំនាន់មុនជីដូនជីតាលួតរបស់យើង ក៏កាន់តែតិចតួចឡើងផងដែរ។ តើអ្នកមិនធ្លាប់គិតទេថា វាពិតជាគួរឲ្យសោកស្តាយណាស់ ប្រសិនបើក្នុងពេលអនាគត សត្វ និងរុក្ខជាតិ ដែលមាននៅតាមដងទន្លេ និងក្នុងព្រៃនៅជុំវិញខ្លួនយើង នឹងត្រូវបាត់បង់ ហើយរឿងព្រេងនិទានទាំងនេះ នឹងត្រូវសាបរលាបបន្តិចម្តងៗចេញពីភូមិរបស់យើង?

កូនសៀវភៅនេះមានរឿងនិទានផ្សេងៗ ដែលត្រូវបានបន្សល់ទុកពីតំបន់មួយ ដែលជាផ្នែក នៃ ប្រទេសថៃ ឡាវ និង កម្ពុជា។ យើងសុំឲ្យអ្នកអានរឿងនិទានទាំងនេះ ហើយធ្វើការពិភាក្សាអំពី បរិស្ថានធម្មជាតិជុំវិញខ្លួនអ្នក។

យើងក៏សង្ឃឹមយ៉ាងមុតមាំផងដែរថា នៅពេលបញ្ចប់សិក្ខាសាលា និងនៅពេលដែលអ្នកត្រឡប់ទៅផ្ទះវិញ អ្នកនឹងព្យាយាមស្នើរសុំឲ្យជីដូនជីតារបស់អ្នក ព្រមទាំងអ្នកផ្សេងទៀតនៅក្នុងសហគមន៍របស់អ្នកនិយាយរឿងនិទានដែលបានដំណាលតៗគ្នានៅក្នុងភូមិរបស់អ្នក។ ស្របពេលជាមួយគ្នានេះដែរ យើងក៏សង្ឃឹមផងដែរថា អ្នកនឹងព្យាយាមសង្កេតមើលវត្ថុមានជីវិត ដែលរស់នៅតាមដងទន្លេ និងនៅក្នុងព្រៃ ហើយគិតអំពីធនធានធម្មជាតិនៅក្នុងតំបន់របស់អ្នក។ អ្នកប្រហែលជានឹងមើលឃើញបរិស្ថានធម្មជាតិជុំវិញខ្លួន ដែលអ្នកនឹងមានភាពស៊ាំជាមួយក្នុងវិធីផ្សេងៗគ្នា។

យើងមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ប្រសិនបើកូនសៀវភៅនេះអាចជួយអ្នកឲ្យគិតបានកាន់តែស៊ីជម្រៅជាងមុនអំពី បរិស្ថានធម្មជាតិរបស់អ្នក។



# រឿងទីទុយ
# និង ក្តាន់

(The Owl and the Deer)

សូមអានរឿងនិទានខាងក្រោម ហើយគិតអំពី សត្វនានានៅតាមដងទន្លេ និងក្នុងព្រៃ

នៅក្នុងស្រុកប៉ាកបេង (Pakbeng) ខេត្តអូដំរ៉ៃ (Oudomxay) ភាគខាងជើងប្រទេសឡាវជនជាតិដើមភាគតិចឃ្មុរ (Kmhmu) ត្រូវបានចាត់ទុកថាមានចំនួនប្រជាជនច្រើនបើធៀបនឹងចំនួនប្រជាជនសរុប។ ក្នុងចំណោមក្រុមកុលសម្ព័ន្ធជនជាតិដើម ដែលកំពុងរស់នៅក្នុងប្រទេសឡាវបច្ចុប្បន្ននេះ ជនជាតិឃ្មុរ បានរស់នៅក្នុងតំប ន់នោះមានរយៈពេលយូរជាងគេ។ របៀបរស់នៅជាទូទៅរបស់ជនជាតិឃ្មុរ គឺពឹងផ្អែកលើការប្រកបរបរកសិកម្ម ជាពិសេសផលិតកម្ម ស្រូវ នៅតាមតំបន់កសិកម្មចម្ការវិលជុំរួមជាមួយការបរបាញ់ ការនេសាទ និងការប្រមូលភោគផលនៅតាមដងទន្លេ និងព្រៃនានា។

អ្នកមីងតុប (Toop) ជាប្រជាពលរដ្ឋ ដែលមានវ័យចំណាស់ម្នាក់ រស់នៅក្នុងភូមិ ចំឡេងណយ (Chom-Leng Noy) ស្រុក ប៉ាកបេង គឺជាអ្នកនិទានរឿងព្រេងបុរាណដ៏ពូកែម្នាក់ប្រចាំភូមិនេះ។

ដោយសារតែគាត់មានវ័យចំណាស់ ហើយមិនអាចប្រកបកសិកម្មចម្ការវិលជុំបានទៀតគាត់ក៏បានចំណាយពេលវេលារបស់គាត់ នៅមើលថែទាំក្មេងតូចៗ ចិញ្ចឹមមាន់ និងប្រមូលផលដំណាំបន្លែពីព្រៃ ដែលនៅជិតៗនេះ។

រឿងនិទានដែលបានរៀបរាប់ដោយអ្នកមីងតុប តែងតែមានការនិយាយអំពី ភាពខុសគ្នានៃសត្វ និងរុក្ខជាតិ។ នៅក្នុងរឿង "ទីទុយ និង ក្តាន់" ខាងក្រោមនេះ មានតួអង្គសត្វព្រៃដូចជាសត្វទីទុយ ក្តាន់ ដំរី ពស់ និងសត្វប្រជៀវ រួមទាំងសត្វកសិក ម្ម ដូចជា សត្វមាន់ ជ្រូក ដោយសត្វទាំងអស់មានជាប់ទំនាក់ទំនងជាមួយមនុស្ស សូម្បីតែសត្វនាគផងដែរ។ មានដើមចេកមួយដើម ដែលដុះនៅក្នុងព្រៃ ហើយក៏ប្រហែលជាមានអ្នកស្រុកនៅតំបន់ចម្ការវិលជុំ បានដាំដើមល្ពៅនៅទីនោះផងដែរ។ នៅក្នុងរឿងព្រេងនិទានរបស់ជនជាតិឃ្មុរ អ្នកស្តាប់នឹងឆ្លងកាត់នូវបទពិសោធន៍ ដ៏ស្រពិចស្រពិលនៃពិភព ដែលនៅជុំវិញខ្លួនរបស់ពួកគេ ហើយមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅ ជាមួយបរិស្ថានធម្មជាតិ ព្រៃឈើ និងទន្លេ ព្រមទាំងកិច្ចការខាងក្នុងជីវិតរបស់ពួកគេ។មានថ្ងៃមួយទីទុយបានអញ្ជើញក្តាន់ទៅស្ទូចត្រីជាមួយគ្នា[1]។នៅពេលពួកគេទៅដល់ទន្លេ ទីទុយក៏បានជ្រើសរើសអូរតូចមួយ ចំណែកក្តាន់ជ្រើសរើសអូរដែលធំជាង ហើយពួកគេប្រើកញ្ច្រែងត្បាញដើម្បីចូកត្រីពីក្នុងអូររៀងៗខ្លួន។ ក្តាន់ចាប់បានត្រី បង្កង និងសត្វជាច្រើនប្រភេទទៀត។ ប៉ុន្តែ ទីទុយវិញបែរជាចាប់មិនបានអ្វីសោះ។ ទីទុយមានការស្រេកឃ្លាន ក៏ងាកទៅរកក្តាន់ហើយនិយាយថា"ហេ! លោកបងក្តាន់ប្រសិនបើ បងឡើងទៅខ្សែទឹកខាងលើ បងអាចចាប់ត្រីបានច្រើនជាងនេះទៅទៀត "ក្តាន់បានតបទៅវិញថា"ពិតមែនឬ? បើសិនជាអញ្ចឹងមែន ខ្ញុំនឹងឡើងទៅចាប់នៅខ្សែទឹកខាងលើ ហើយបន្តិចទៀតខ្ញុំនឹងត្រឡប់មកវិញ។"

ក្តាន់ទុកចោលត្រីដែលចាប់បាន ហើយក៏ឡើងទៅខ្សែទឹកខាងលើ។ នៅពេលដែលក្តាន់បានឡើងទៅឆ្ងាយរហូតដល់មើល លែ ងឃើញ ទីទុយបានស៊ីត្រីដែលក្តាន់ចាប់បានអស់ ហើយនៅពេលដែលក្តាន់ត្រឡប់មកវិញ គេមិនបានឃើញត្រីដែលខ្លួនខិតខំចាប់សោះ នៅសល់តែបង្កងដែលទីទុយមិនបានស៊ី។ ពេលនោះខ្លួនដឹងថា បាន ចា ញ់បោកទីទុយ ក្តាន់ក៏បានទន្ទ្រាំជើងដោយកំហឹងជាខ្លាំង។ នៅពេលទន្ទ្រាំជើងនេះ ក្រចកជើងរបស់ក្តាន់បានទាក់នឹងវល្លិល្ពៅដោយអចេតនា ហើយក៏បានធ្វើឲ្យផ្លែល្ពៅរមៀលធ្លាក់តាមជម្រាលភ្នំ។ ផ្លែល្ពៅបា ន រមៀលត្រង់ទៅដល់កន្លែង ដែលលោកយាយម្នាក់កំពុងតែបង្កាត់ភ្លើងដាក់ដាំទឹក ផ្លែល្ពៅបាន

រមៀលទៅប៉ះក្រឡាប់ឆ្នាំងធ្វើឲ្យទឹក ដែលកំពុងដាំកំពប់លើជើងរបស់លោកយាយនោះ។ លោកយាយមានការខឹងសម្បារ ដោយសាររលាកទឹកក្ដៅគាត់ ក៏បានវាយស្គរដែលនៅក្បែរនោះឮយ៉ាងខ្លាំង។

សត្វមាន់មួយក្បាលដែលនៅជិតនោះភ័យស្លន់ស្លោរនឹងសម្លេងស្គរក៏ផ្អើល ហើយហោះទៅបុកជន្លួញ ដែលបញ្ឈរទុកចោល(សម្រាប់ប្រើប្រាស់ចោះរន្ធដីនៅពេលសាបព្រួស)។ ជន្លួញក៏បានដួលរលំទៅលើសត្វពស់មួយក្បាល ។ ដោយមានការភ្ញាក់ផ្អើល សត្វព ស់ ចាប់ផ្ដើមរមាលរមូលភ័យស្លន់ស្លោរ ក៏លូនយ៉ាងលឿនកាត់សំបុកស្រមោចឡើងខូចខ្ទេចខ្ទីអស់។

ស្រមោចនៅក្នុងសំបុកដែលខូចខ្ទេចខ្ទី ក៏ផ្អើលវារឡើងលើភ្លាមៗមកកាន់សត្វជ្រូក ដែលនៅជិតនោះ ហើយបានខាំមាត់សត្វជ្រូក។ នៅពេលដែលស្រមោចខាំ សត្វជ្រូកខំរលាស់ស្រមោចចេញ និងឈ្មុលមាត់ទៅបុកនឹងដើមចេក។ សត្វជ្រូកឈ្មុលកាន់តែខ្លាំង ធ្វើឲ្យដើមចេក រលំ។ សត្វប្រជៀវកំពុងតែដេកក្នុងដើមចេកនោះមានការផ្អើល ក៏ហើរទៅចូលក្នុងត្រចៀកដំរីមួយចំហៀង។ ដល់វេនដំរីភ័យស្លន់ស្លោរ ហើយក៏ទាត់មែកឈើហោះឡើងទៅលើ រួចធ្លាក់ចុះទៅបុកភ្នែករបស់កូនសត្វនាគ ដែលកំពុងហែលទឹកក្នុងទន្លេ។ នៅពេលឮសម្លេងកូនរបស់ខ្លួនយំ ដោយសារតែរបួសភ្នែក មេរបស់កូននាគនោះ ក៏ប្រញាប់ប្រញាល់ចេញមកមើលទាំងភ័យស្លន់ស្លោរ។

មេរបស់កូននាគបានសួរថា "ព្រះអើយ! តើកូនមានអ្វីកើតឡើងហ្នឹង?" កូននាគឆ្លើយថា"មានមែកឈើហោះមកបុកភ្នែកកូន"។ មេនាគ ទៅសួររកអ្នក បង្ករហេតុ (មែកឈើ)មេនាគសួរថា៖ "នែ៎មែកឈើ!ហេតុអ្វីក៏ឯងហោះមកបុកភ្នែកកូនយើងអញ្ចឹង?" មែកឈើនិយាយថា៖ "ដោយសារតែបងដំរីទាត់ខ្ញុំ អញ្ចឹងហើយបានជាខ្ញុំហោះមកបែបនេះ"មេនាគងាកមកសួរដំរីថា៖ "លោកបងដំរី! ហេតុអ្វីបានជាលោកបងទាត់មែកឈើអញ្ចឹង?" ដំរីឆ្លើយភ្លាមថា៖ "ដោយសារតែរំពេចមួយនោះ សត្វប្រជៀវហោះចូលត្រចៀករបស់ខ្ញុំ ហើយពេលនោះខ្ញុំភ័យស្លន់ស្លោរពេក" មេនាគសួរប្រជៀវថា៖ "ប្រជៀវ! ហេតុអ្វីបានជាឯងហោះចូលត្រចៀកបងដំរីដូច្នេះ?" ប្រជៀវតបវិញថា៖ "គឺដោយសារដើមចេក ដែលខ្ញុំកំពុងដេកលើនោះបានដួលរលំ" មេនាគសួរតទៅទៀតថា៖ "ដើមចេក! នៅសុខៗហេតុអ្វីបានជាឯងដួលរលំអញ្ចឹង?" ដើមចេកតបថា៖ "ពីព្រោះសត្វជ្រូកបានយកមាត់ឈ្មុលមកលើខ្ញុំ" មេនាគសួរជ្រូកថា៖ "នែ៎ជ្រូក! ហេតុអ្វីបានជាឯងយកមាត់មកឈ្មុលមកលើដើមចេកយ៉ាងនេះ?" ជ្រូកតបថា៖ "មូលហេតុគឺដោយសារតែសត្វស្រមោចខាំមាត់របស់ខ្ញុំ។"



មេនាគសួរស្រមោចថា៖ “ស្រមោច! ហេតុអ្វីបានជាឯងខាំជ្រូកអញ្ចឹង?” ស្រមោចឆ្លើយផូងថា៖ “មកពីសត្វពស់បានបំផ្លាញសំបុករបស់យើង” មេនាគងាករកពស់ “នែ៎ពស់! ហេតុអ្វីបានជាឯងបំផ្លាញសំបុករបស់សត្វស្រមោចដូច្នេះ?” ពស់តបដោយស្មៀមស្ងាត់ថា៖“ ដោយសាររំពេចនោះខ្ញុំតក់ស្លុតនឹងសំលេងជន្លួញរលំពេក” ងាកមកជន្លួញ មេនាគសួរបន្តថា៖ “ជន្លួញ! ហេតុអ្វីបានជាឯងដួលរលំទៅលើសត្វពស់អញ្ចឹង?” ជន្លួញឆ្លើយថា៖ “មូលហេតុគឺដោយសារតែសត្វមាន់ហោះមកបុកខ្ញុំ?”មេនាគសំលឹងមេមាន់រួចសួរថា៖ “អ្នកនាងមាន់! ហេតុអ្វីបានអ្នកនាងហោះមកបុកជន្លួញដូច្នេះ? ”មេមាន់លាកន្ទុយរួចឆ្លើយថា៖ “ដោយសារតែរំពេចនោះលោកយាយចាប់ផ្តើមវាយស្គរ” មេនាគទ្រឹងមួយសន្ទុះរួចសួរថា៖ “លោកយាយ! ហេតុអ្វីបានជាលោកយាយវាយស្គរ?” លោកយាយនិយាយថា៖ “ពីព្រោះខ្ញុំភ្ញាក់ផ្អើលនៅពេល ដែលឆ្នាំងក្រឡាប់កំពប់ទឹកក្តៅត្រូវជើងខ្ញុំ” មេនាគសួរទៀតថា៖ “ឆ្នាំង! ហេតុអ្វីបានជាឯងក្រឡាប់អញ្ចឹង?”ឆ្នាំងឆ្លើយថា៖ “ដោយសារតែផ្លែល្ពៅបានធ្លាក់ចុះមកពីជម្រាលភ្នំ។
”មេនាគសួរបន្តរថា៖ “ល្ពៅ! ហេតុអ្វីបានជាឯងរមៀលធ្លាក់ចុះមកពីជម្រាលភ្នំដូច្នោះ? ”ល្ពៅឆ្លើយតបថា៖ “ដោយសារតែសត្វក្តាន់ទាក់ផ្តាច់ឫសរបស់ខ្ញុំ” មេនាគសួរទៀតថា៖ “លោកបងក្តាន់! ហេតុអ្វីបានជាលោកបង ទាក់ផ្តាច់ឫសរបស់ល្ពៅអញ្ចឹង?” សត្វក្តាន់ឆ្លើយផូងថា៖ “ពីព្រោះទីទុយលួចត្រីរបស់ខ្ញុំអស់ ហើយខ្ញុំខឹងពេក” ចុងក្រោយ មេរបស់កូននាគក៏ឆ្ពោះទៅដល់ទីទុយ ហើយសួរថា៖ “ទីទុយ! ហេតុអ្វីបានជាឯងលួចត្រីរបស់សត្វក្តាន់អញ្ចឹង?” ទីទុយមិនអាចគិតឃើញយ៉ាងម៉េច ដើម្បីពន្យល់ហេតុផលណាមួយបាន។ ដោយសារមិនអាចឆ្លើយបាន គេក៏សម្លឹងមើលចុះឡើងជាមួយភ្នែកធំៗរបស់គេ។ មេនាគបាននិយាយថា “ឯងត្រូវតែមានទោសដោយសារតែឯង ទើបភ្នែករបស់កូនយើងត្រូវខូច យើងនឹងយកភ្នែកឯងម កជំនួសវិញ”។ ថារួចមេនាគ ក៏ស្ទុះទៅខ្វេះគ្រាប់ភ្នែកសត្វទីទុយ ហើយយកមកដាក់ក្នុង រន្ធភ្នែករបស់កូនខ្លួនវិញ។ បន្ទាប់មកមេនាគបានយកគ្រាប់ផ្លែឈើម៉្យាងមានឈ្មោះថាសាឡែន (Sal aen) មកដាក់បំពេញភ្នែកឲ្យសត្វទីទុយវិញ ដែលអាចឲ្យទីទុយមើលឃើញតែពេលយប់ប៉ុណ្ណោះ។ ចាប់ពីពេលនោះមកសត្វទីទុយមិនអាចមើលឃើញនៅពេលថ្ងៃបានទៀតទេ។

---ចប់---

[1] តួអង្គក្ដាន់នៅក្នុងរឿងនិទាននេះគឺជា ក្ដាន់ (មួនត្យាស muntjac) ដែលជាពូជសត្វក្ដាន់តូចៗ ដែលគេហៅថា ហ្វែន (Fahn) នៅក្នុងប្រទេសឡាវ ឬ ភួអៃ (Puai) នៅក្នុងក្រុមជនជាតិដើមភាគតិចឃ្មុះ (Kmhmu)។



# ថ្នាក់ទី ១ ដល់ថ្នាក់ទី ៤

**គោលបំណង**

- យល់ដឹងអំពី រុក្ខជាតិ និង សត្វផ្សេងៗ ដែលនៅជុំវិញខ្លួនយើង
- បង្កើតអារម្មណ៍ស្និទ្ធស្នាលជាមួយរុក្ខជាតិ និងសត្វទាំងឡាយ ដែលរស់នៅជុំវិញយើង ហើយបណ្តុះក្តីស្រឡាញ់ចំពោះរុក្ខជាតិ និងសត្វទាំងនោះ ព្រមទាំងមានអារម្មណ៍ចង់ថែ រក្សាពួកវាឲ្យបានល្អ។

សកម្មភាពក្នុងថ្នាក់ (ត្រូវការរយៈពេល ៖ ពី ៣០ នាទី ទៅ ៤០ នាទី)

១. អ្នកសម្របសម្រួលសួរសំណួរទៅកាន់សិស្សថា "តើអ្នកចូលចិត្តសត្វ (រុក្ខជាតិ)អ្វី?" សិស្ស អាចឆ្លើយដោយផ្ទាល់មាត់ម្តងម្នាក់ៗ ឬអាចគូររូបភាព បង្ហាញដល់សិស្សផ្សេងទៀតនៅក្នុង ក្រុម។

២.បន្ទាប់មក អ្នកសម្របសម្រួលចាប់ផ្តើមនិទានរឿងដោយនិយាយថា "ខ្ញុំនឹងអានរឿងមួយ ឲ្យប្អូនស្តាប់ ដែលនៅក្នុងរឿងនេះមានតួអង្គជា សត្វ (វត្ថុមានជីវិត) ផ្សេងៗ សម្តែងក្នុងរឿង។ តើប្អូនគិតថានឹងមានសត្វ (វត្ថុមានជីវិត)អ្វីខ្លះ ដែលមាននៅក្នុងរឿង? សូមស្តាប់រឿងនិទាន ដោយយកចិត្តទុកដាក់" បន្ទាប់មកអ្នកសម្របសម្រួល អានរឿងឲ្យឮៗ។

៣. អ្នកសម្របសម្រួលសួរសិស្សថា "តើមានសត្វ (វត្ថុមានជីវិត) អ្វីខ្លះមាននៅក្នុងរឿង?" អ្នកសម្របសម្រួល ត្រូវសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។ ប្រសិនបើ សិស្សមិនបាន លើកឡើងអំពី សត្វ (វត្ថុមានជីវិត) មួយចំនួននោះទេ អ្នកសម្របសម្រួល ត្រូវនិយាយលើកឡើង អំពី ឈ្មោះសត្វ (វត្ថុមានជីវិត)ទាំងនោះ ដោយនិយាយ "ខ្ញុំគិតថាមាន... នៅក្នុងរឿងនេះដែរ មិនអញ្ចឹង?" ដូច្នេះ សិស្សត្រូវបានរំឭកអំពី សត្វ (វត្ថុមានជីវិត) ទាំងអស់ ដែលមាននៅក្នុងរឿង នេះ។ អ្នកសម្របសម្រួល ត្រូវសរសេរចម្លើយរបស់សិស្សនៅលើក្តាខៀន។

៤. បន្ទាប់មកទៀត អ្នកសម្របសម្រួលសួរសិស្សថា "តើរុក្ខជាតិ និងសត្វ (វត្ថុមានជីវិត) ទាំងនេះ ណាមួយដែលរស់នៅក្បែរភូមិរបស់យើង?" ឈ្មោះរបស់រុក្ខជាតិ និងសត្វទាំងអស់ ដែលសិស្ស បានផ្តល់ចម្លើយ ត្រូវសរសេរដាក់លើក្តារខៀន។

៥. បន្ទាប់មកទៀត អ្នកសម្របសម្រួលបន្តសួរសិស្សថា "តើមានរុក្ខជាតិ ឬសត្វ (វត្ថុមានជីវិត) ណាខ្លះទៀត ដែលយើងអាចមើលឃើញនៅជុំវិញភូមិរបស់យើង?" រួចសរសេរដាក់លើក្តារខៀននូវឈ្មោះរបស់ រុក្ខជាតិ និងសត្វទាំងអស់ ដែលសិស្សបានផ្តល់ចម្លើយ។

៦. អ្នកសម្របសម្រួលជ្រើសរើសចំនួន រុក្ខជាតិ និងសត្វ (វត្ថុមានជីវិត) ដែលសិស្សបានផ្តល់ ចម្លើយ រួចសួរសិស្សថា "តើរុក្ខជាតិ និងសត្វ (វត្ថុមានជីវិត)ទាំងនោះ ត្រូវបានប្រើប្រាស់ (មានប្រយោជន៍) សម្រាប់ធ្វើអ្វីខ្លះ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ យើង?"

៧. អ្នកសម្របសម្រួលសួរសិស្សថា "នៅក្នុងរឿងនេះ សត្វទីទុយ ដែលជាអ្នកត្រូវទទួលខុសត្រូវចំពោះដើមចម ដែលបណ្តាលឲ្យភ្នែករបស់កូននាគមានរបួស ដែលត្រូវទទួលទោស យ៉ាងធ្ងន់ធ្ងរ នៅចុងបញ្ចប់នៃរឿងនេះ ប៉ុន្តែតើអ្នកគិតរឿងដូចគ្នានេះនឹងកើតមានឡើងជាក់ស្តែងនៅក្នុង សង្គមបច្ចុប្បន្នរបស់យើងដែរឬទេ?" បន្ទាប់មក អ្នកសម្របសម្រួលសួរថា "ឧទាហរណ៍ ទីទុយ ព្រៃរស់នៅក្នុងព្រៃ ប្រសិនបើមនុស្សកាប់រំលំដើមឈើនៅក្នុងព្រៃនោះ ទីទុយនឹងមានចំនួនតិច តួចរស់នៅទីនោះ ឬ ទីទុយកាន់តែមានចំនួនថយចុះ?" "វាអាចប្រហែលជា ទីទុយមួយចំនួន នឹងមិនរស់នៅទីនោះទៀតទេ មិនអញ្ចឹង?" ប្រសិនបើគ្មាន ទីទុយបន្ថែមទៀត នៅក្នុងព្រៃទេ

តើនឹង មានរឿងអ្វីកើតឡើង ចំពោះសត្វកណ្ដុរ ដែលទីទុយតែងតែស៊ីជាអាហារ?" "នឹងមានកណ្ដុរកាន់ តែច្រើនមែនទេ? ហើយតើនឹងមានអ្វីកើតឡើង ប្រសិនបើមាន កណ្ដុរកាន់តែច្រើននោះ?" "កណ្ដុរនឹងស៊ីស្រូវ។ តើនរណាជាអ្នកត្រូវរងទុក្ខ នៅពេលមានរឿងបែបនេះ កើតឡើង?" និយាយទៅកាន់សិស្សថា "នៅទីបញ្ចប់ នឹងមានអាហារកាន់តែតិចតួច សម្រាប់ មនុស្សយើង បរិភោគ ដូច្នេះចុងក្រោយមនុស្ស ដែលជាអ្នកបានកាប់រំលំដើមឈើនោះ ហើយ គឺជាអ្នកត្រូវ រងទុក្ខ។" (*សកម្មភាពមួយដែលអាចធ្វើទៅបាន ចូររៀបចំជាមុននូវ ប័ណ្ណក្រដាសមួយដុំដែលមានបង្ហាញរូបភាព "មនុស្សកំពុងកាប់រំលំដើមឈើ" "ដើមឈើកាន់តែតិចនៅក្នុងព្រៃ" "ទីទុយ កាន់តែតិចតួច" "កណ្ដុរកាន់តែច្រើន" ហើយ "អាហារសម្រាប់មនុស្សមានកាន់តែតិចតួច"។ ចែក ប័ណ្ណក្រដាសទាំងនោះចំនួនមួយឈុតឲ្យក្រុមសិស្ស ហើយសុំឲ្យសិស្សទាំងនោះ រៀបប័ណ្ណ ទាំងនេះ តាមលំដាប់ ហេតុផលបង្ករ និងផលប៉ះពាល់)។

៨. នៅពេលសំដៅដល់ "សត្វ (ឬ រុក្ខជាតិ) ដែលពេញចិត្ត" ហើយស្នើសុំតាំងពីពេលចាប់ផ្ដើមសកម្មភាព រួចសង្ខេបសកម្មភាពដោយបញ្ជាក់ឃ្លាខាងក្រោមជាមួយសិស្ស។ "មានសត្វ (វត្ថុ មានជីវិត) ជាច្រើននៅជុំវិញពួកយើង។" "ពួកវាទាំងនោះ រស់នៅជាមួយមនុស្សនៅក្នុងភូមិ និងតំបន់នេះ។"

រុក្ខជាតិ និងសត្វ ដែលមាននៅក្នុងរឿងដូចជា៖

| | | |
|---|---|---|
| ទីទុយ | ក្ដាន់ | ដំរី |
| ពស់ | ប្រជៀវ | មាន់ |
| ជ្រូក | លោកយាយ (មនុស្ស) | នាគ |
| ត្រី | ល្ពៅ | ចេក |

ចំណុចគន្លឹះ៖

- រៀបចំផ្ទាំងក្រដាសរូបភាព រុក្ខជាតិ និងសត្វ ដែលមាននៅក្នុងរឿងនេះ ហើយបិទរូបភាពទាំងនេះនៅលើក្ដារខៀន ក្នុងពេលកំពុងអានរឿងឲ្យសិស្សក្នុងក្រុមស្ដាប់។ ការធ្វើបែបនេះ នឹងធ្វើឲ្យសិស្សកាន់តែងាយស្រួលយល់សាច់រឿង ហើយយកចិត្តទុកដាក់ ចំពោះសត្វ ខុសៗគ្នា ដែលមាននៅក្នុងរឿងនេះ។
- ការប្រើប្រាស់រូបតុក្កតានៅពេលកំពុងនិទានរឿង ក៏ជាការល្អផងដែរ។



# ថ្នាក់ទី ៥ ដល់ថ្នាក់ទី៦ សាលាមធ្យមសិក្សាបឋមភូមិ

គោលបំណង

- កត់សម្គាល់ និងយល់ដឹងអំពីការពិតថា រុក្ខជាតិ និងសត្វជាច្រើន ដែលនៅជុំវិញខ្លួន កាន់តែ តិចតួចទៅៗ បើប្រៀបធៀបជាមួយអតីតកាល។
- កត់សម្គាល់ និងយល់ដឹងអំពីការពិតថា ការពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់មនុស្ស (ការអភិវឌ្ឍន៍)និងការផ្លាស់ប្តូររបៀបរស់នៅ មានទំនាក់ទំនងជាមួយនឹងការផ្លាស់ប្តូរ បរិមាណ បរិស្ថានធម្មជាតិ ។

សកម្មភាពទី ១) (ត្រូវការរយៈពេល ៖ ប្រហែល ១ម៉ោង)

១. អ្នកសម្របសម្រួលចាប់ផ្តើមរឿងនិទាន ដោយនិយាយថា "ខ្ញុំនឹងអានរឿង និទានមួយឲ្យ ប្អូនៗស្តាប់ដែលក្នុងរឿងនោះ មានប្រភេទរុក្ខជាតិ និងសត្វ (វត្ថុមានជីវិត) ផ្សេងៗជាច្រើន។ តើសត្វ (វត្ថុមានជីវិត) អ្វីខ្លះដែលប្អូនគិតថានឹងមាននៅក្នុងរឿងនេះ? សូមស្តាប់រឿងនេះ ដោយយកចិត្តទុកដាក់។" បន្ទាប់មកអ្នកសម្របសម្រួលអានរឿងឲ្យឮៗ។

២. បន្ទាប់មកទៀត អ្នកសម្របសម្រួលសួរសិស្សថា "តើមានរុក្ខជាតិ និងសត្វ (វត្ថុមានជីវិត)អ្វីខ្លះ នៅក្នុងរឿងនេះ?" ត្រូវសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។ ប្រសិនបើ សិស្ស មិនបានលើកឡើងអំពី សត្វ (វត្ថុមានជីវិត) មួយចំនួន អ្នកសម្របសម្រួលត្រូវលើក ឡើងអំពី សត្វ (វត្ថុមានជីវិត)ទាំងនោះ នៅពេលកំពុងសរសេរឈ្មោះសត្វ (វត្ថុមានជីវិត) ផ្សេងទៀតនៅលើក្តារខៀន ដោយនិយាយ "ខ្ញុំគិតថាមាន... នៅក្នុងរឿងនេះដែរ មិនអញ្ចឹង?" ដូច្នេះសិស្សត្រូវបានរំឭកអំពី សត្វ (វត្ថុមានជីវិត) ទាំងអស់ ដែលមាននៅក្នុងរឿងនេះ។

៣. អ្នកសម្របសម្រួលសួរសិស្សថា "តើរុក្ខជាតិ និងសត្វទាំងអស់នេះ ណាមួយ ដែលយើង អាចរកបាននៅក្បែរភូមិរបស់យើង?"

៤. បន្ទាប់មកទៀត អ្នកសម្របសម្រួលបន្តសួរសិស្សថា "ក្រៅពី រុក្ខជាតិ ឬសត្វ (វត្ថុមានជីវិត) ទាំងអស់នេះ តើមានសត្វ និងរុក្ខជាតិណាខ្លះទៀត ដែលយើងអាចមើល ឃើញនៅ ជុំវិញភូមិរបស់យើង?" ឈ្មោះរបស់រុក្ខជាតិ និងសត្វទាំងអស់ ដែលសិស្សបានឆ្លើយ ត្រូវ សរសេរដាក់នៅលើក្តារខៀន។

៥. អ្នកសម្របសម្រួលជ្រើសរើសចំនួន រុក្ខជាតិ និងសត្វ (វត្ថុមានជីវិត) ទាំងអស់ ដែលសិស្ស បានឆ្លើយ រួចសួរថា "តើ រុក្ខជាតិ និងសត្វ (វត្ថុមានជីវិត)ទាំងនោះ ត្រូវបានប្រើប្រាស់ (មានប្រយោជន៍) បែបណាដែរ នៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើង?"

៦. បន្ទាប់មកទៀត អ្នកសម្របសម្រួលសួរសិស្សថា "ក្នុងចំណោម រុក្ខជាតិ ឬសត្វ ទាំងនេះ តើមានរុក្ខជាតិ ឬសត្វណាខ្លះ ដែលមិនសូវបានឃើញជាញឹកញាប់ នៅក្នុងពេលបច្ចុប្បន្ន កាល ឬផុតពូជទាំងស្រុង ដែរឬទេ?"

៧. បន្ទាប់មកទៀត អ្នកសម្របសម្រួលសួរថា "ហេតុអ្វីបានជាអ្នកគិតថា រុក្ខជាតិ ឬសត្វ ទាំងនេះ មិនសូវបានឃើញញឹកញាប់ ឬផុតពូជទាំងស្រុង?" ត្រូវសរសេរចម្លើយរបស់សិស្ស នៅលើក្តារខៀន។

៨. បន្ទាប់មក អ្នកសម្របសម្រួលសួរថា "តើអ្នកគិតថានឹងមានអ្វីកើតឡើង ប្រសិនបើ រុក្ខជាតិ និងសត្វទាំងនេះ ត្រូវផុតពូជ?" ត្រូវសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។

៩. អ្នកសម្របសម្រួលសួរសិស្សថា "នៅក្នុងរឿងនេះ សត្វទីទុយ ដែលត្រូវទទួលខុសត្រូវ ចំពោះដើមចមដែលបណ្តាលឲ្យភ្នែករបស់កូននាគ មានរបួស ត្រូវទទួលទោសយ៉ាងធ្ងន់ធ្ងរ នៅចុងបញ្ចប់នៃសាច់រឿងនេះ ប៉ុន្តែតើអ្នកគិតរឿងដូចគ្នានេះ នឹងកើតមានឡើងជាក់ស្តែង នៅក្នុងសង្គមរបស់យើងដែរឬទេ? " ប្រសិនបើ មនុស្សបំផ្លាញបរិស្ថានដើម្បីតម្រូវការផ្ទាល់របស់ខ្លួននោះ ជួនកាលពួកគេនឹងត្រូវប្រឈមមុខនឹងផលវិបាកធ្ងន់ធ្ងរ ចំពោះសកម្មភាព របស់ខ្លួន។ **ចូរគិតអំពីរឿងទាំងនេះ ដែលបង្ហាញអំពី អ្វីដែលមនុស្សអាចធ្វើបាន។**

១០. ចូររៀបចំប័ណ្ណក្រដាស ដែលមានបង្ហាញរូបភាព ឧទាហរណ៍ "ការកាប់រំលំដើមឈើ នៅក្នុងព្រៃ" "ការចោលសំរាមនៅលើដងផ្លូវ" "ការបញ្ចេញចោលទឹកកខ្វក់ទៅក្នុងទន្លេ"។ល។
ហើយឲ្យក្រុមនីមួយៗបង្កើតរឿង ដែលចាប់ផ្ដើមជាមួយប័ណ្ណក្រដាសនីមួយៗ។ ប្រសិនបើ សិស្សមិនអាចគិតអំពី គំនិតនេះដោយងាយស្រួលនោះ ចូរផ្ដល់ឧទាហរណ៍អំពី ការកាប់ បំផ្លាញព្រៃឈើ និងការផុតពូជសត្វទីទុយពីសំណួរទី ៧ នៅក្នុងផ្នែកថ្នាក់ទី ១ ដល់ថ្នាក់ទី ៤ ដើម្បីជាគម្រូ។ ឲ្យក្រុមសិស្សនីមួយៗ បង្ហាញរឿងរបស់ខ្លួនដល់សិស្សទាំងអស់នៅក្នុងថ្នាក់។

១១. អ្នកសម្របសម្រួលសួរថា "តើអ្នកគិតថា តើយើងគួរធ្វើដូចម្ដេចខ្លះ ដើម្បីការពារកុំឲ្យសត្វ ទាំងនេះ កាន់តែថយចុះ ឬកុំឲ្យផុតពូជ?" ចម្លើយរបស់សិស្ស ត្រូវបានសរសេរម្ដងទៀត នៅលើក្ដារខៀន។

១២. សង្ខេបសកម្មភាពតាមរយៈ ការបញ្ជាក់សង្ខេបសកម្មភាព តាមរយៈការបញ្ជាក់ឃ្លា ខាងក្រោមជាមួយសិស្ស។ "មានរុក្ខជាតិ និងសត្វ (វត្ថុមានជីវិត) ជាច្រើននៅជុំវិញពួក យើង។" "ពួកវាទាំងអស់នោះ រស់នៅរួមជាមួយយើងនៅក្នុងភូមិ និងតំបន់នេះ។" "ការថយចុះនូវចំនួនសត្វ និង រុក្ខជាតិទាំងនេះ មានជាប់ពាក់ព័ន្ធនឹងរបៀបរស់នៅរបស់យើង" "យើង អាចធ្វើការមួយចំនួន ដើម្បីការពារសត្វទាំងនេះ"។

សកម្មភាពទី ២) បទសម្ភាសន៍ (ត្រូវការរយៈពេល ៖ សកម្មភាពមុនបទសម្ភាសន៍ + មួយម៉ោង)

១. សួរសំណួរថា តើមានរុក្ខជាតិប្រភេទណាខ្លះ ដែលកំពុងដាំដុះ ឬសត្វប្រភេទណាខ្លះ ដែលកំពុងរស់នៅក្នុងព្រៃ និងក្បែរដងទន្លេនេះកាលពីមុន តាមរយៈការសួរ លោកតា ឬ លោកយាយរបស់អ្នកអំពីរឿងនេះ។

២. អនុវត្តជំហានទី ១ ដល់ទី ៥ ពីសកម្មភាពទី ១។

៣. សរសេរ រួចធ្វើចំណាត់ថ្នាក់ រុក្ខជាតិ និងសត្វ ដែលមាននៅក្នុងរឿងនេះ នឹងត្រូវបានលើកឡើងនៅក្នុងពេលសម្ភាសន៍ជាមួយ លោកតា ឬលោកយាយរបស់អ្នក។ (ចំណុចនេះអាច ធ្វើឡើង ជាក្រុមតូចៗ ឬជាមួយក្រុមធំទាំងមូល។)

៤. អ្នកសម្របសម្រួលសួរសិស្សថា "តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះ រុក្ខជាតិ និងសត្វ ដែលមិនសូវឃើញមានឬរុក្ខជាតិនិងសត្វដែលបានផុតពូជ?តើលោកតាឬលោកយាយរបស់អ្នកនិយាយអំពីរឿងនេះនៅឯណាដែរ?" សរសេរចម្លើយរបស់សិស្ស នៅលើក្ដារខៀន។

៥. អនុវត្តជំហានទី ៩ និង ១០ ពីសកម្មភាពទី ១។

| វត្ថុមានជីវិតនៅក្នុងធម្មជាតិដែលមាន នៅក្នុងរឿងនេះ | វត្ថុមានជីវិតនៅក្នុងធម្មជាតិដែលមាននៅក្នុងការសម្ភាសន៍ | វត្ថុមានជីវិតនៅក្នុងធម្មជាតិដែលមិន សូវឃើញមាននៅក្នុងពេលបច្ចុប្បន្ន | វត្ថុមានជីវិតនៅក្នុងធម្មជាតិ ដែលធ្លាប់ឃើញកាលពីមុនហើយបានផុតពូជក្នុងពេលបច្ចុប្បន្ន |
|---|---|---|---|
| | | | |

សកម្មភាពទី ៣) លំដាប់ពេលវេលាអនាគត (ត្រូវការរយៈពេល៖ ប្រហែលជា ៩០នាទី

១. អនុវត្តជំហានទី ១ ដល់ ៨ ពីសកម្មភាព ១)

២. សួរសិស្ស "វត្ថុមានជីវិតមួយចំនួន (ប្រាប់ឈ្មោះ រុក្ខជាតិ ឬសត្វជាក់លាក់មួយ ដែលបានលើកឡើងនៅក្នុងបទសម្ភាសន៍ឧទាហរណ៍ "ត្រីអណ្ដែង") បច្ចុប្បន្នមិនសូវមាន ដូចកាលពី មុនឡើយ ប៉ុន្តែតើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះត្រីអណ្ដែង នៅពេលអនាគត? តើ អ្នកគិតថាចំនួនត្រីនេះនឹងកើនឡើង ឬថយចុះ?"

៣. និយាយទៅកាន់សិស្ស "ចូរគិតអំពីអនាគតរបស់ត្រីអណ្តែង (ឬវត្ថុមានជីវិត ផ្សេងទៀត)"។ គូរទម្រង់លម្អិតនៃដ្យាក្រាម ដែលបង្ហាញខាងក្រោម នៅលើក្តារខៀន ដោយចាប់ ផ្តើមពី "អតីតកាល" នៅខាងឆ្វេង។

៤. ចូរសរសេរអំពីអ្វី ដែលបានកើតឡើង ចាប់តាំងពីអតីតកាលរហូតដល់ពេលបច្ចុប្បន្ន

៥. សួរសិស្សថា តើរឿងអ្វីខ្លះដែលអាចកើតឡើង ដើម្បីសរសេរចូលក្នុងបន្ទាត់វេលា ចាប់ពី "បច្ចុប្បន្ន" រហូតដល់ "អនាគត ខ្ញុំមិនចង់ឃើញ – ត្រីអណ្តែងផុតពូជឡើយ" ហើយចូរសរសេរ ចម្លើយទាំងនោះនៅលើដ្យាក្រាម។

៦. បន្ទាប់មក ឲ្យសិស្សផ្តល់គំនិតយោបល់របស់ខ្លួនថា តើយើងអាចធ្វើអ្វីបានខ្លះ ឬត្រូវមាន អ្វីខ្លះកើតឡើង ដើម្បីឲ្យបន្ទាត់ពេលវេលា "បច្ចុប្បន្ន" ដល់ "អនាគត ខ្ញុំចង់ឃើញ –សម្បូរត្រី អណ្តែង" ហើយសរសេរគំនិតយោបល់ទាំងនោះទៅក្នុងដ្យាក្រាម។

៧. ពិនិត្យមើលទូទៅលើដ្យាក្រាម ដែលបានបំពេញ ហើយសង្ខេបសកម្មភាព ដោយ និយាយអំពីអ្វីដែលបានកើតឡើង (ចាប់ពីអតីតកាលដល់បច្ចុប្បន្ន) នាំឲ្យមាន ស្ថានភាពដូច ពេលបច្ចុប្បន្ន និងអ្វីដែលយើងត្រូវតែធ្វើ ឬអ្វីដែលយើងចាំបាច់ត្រូវសម្រេច ឲ្យបាន ដើម្បីនាំ មកនូវអនាគត ឲ្យសំបូរត្រីអណ្តែងនៅក្នុងទន្លេ។

ឧទាហរណ៍៖ ក្នុងករណីត្រីអណ្តែងមានការថយចុះ៖





# ប្រវត្តិស្រុក កែវ សីមា

# (History of Keo Seima District)



សូមអានរឿងនិទានខាងក្រោម ហើយគិតអំពីប្រពៃណី និងពិធីបុណ្យសាសនា ដែលបានបន្សល់ទុកនៅក្នុងតំបន់នេះ

*រឿងនេះត្រូវបាននិទានដោយលោកតា* កែវ ភ្លើយ និងលោកយាយ តេត យេត នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៤។ លោកតា កែវ ភ្លើយ មានអាយុ ៨០ឆ្នាំ ហើយបច្ចុប្បន្នកំពុងរស់នៅក្នុងភូមិទ្បៅកា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។

ជាយូរលុងណាស់មកហើយ នៅលើភ្នំមួយ អ្នកភូមិបានមើលឃើញ នៅលើថ្មភ្នំមានដុះថ្មមានរាងជាកែវជាច្រើន កែវនោះមានរាងជាកែវចរណៃ មានពន្លឺចែងចាំងគ្រប់ពណ៌ដូចពន្លឺពេជ្រចរណៃ វាជាថ្មកែវស្អាតខ្លាំងណាស់។ អ្នកភូមិហៅថ្មកែវនោះថា កែវ សីមា ឬកែវទិព្វ។

តំបន់នៅលើភ្នំគឺជាកន្លែង ដែលអ្នកភូមិលែងគោក្របីឲ្យស៊ីស្មៅ ហើយសត្វគោក្របីទាំងនេះមិនដែលបាត់បង់ទេ។ អ្នកភូមិតែងតែបន់ស្រន់អ្នកតាម្ចាស់ស្រុក ឲ្យជួយថែរក្សាគោក្របីរបស់ខ្លួន។

នៅពេលណាដែលមានបាត់គោក្របី អ្នកភូមិក៏តែងតែធ្វើការបន់ស្រន់សុំអ្នកតាម្ចាស់ស្រុក ឲ្យជួយរកឲ្យឃើញសត្វរបស់ពួកគាត់ទាំងនោះមកវិញ។ ពីរបីថ្ងៃបន្ទាប់មក សត្វគោក្របីទាំងនេះក៏ត្រឡប់មកវិញ។

ដូច្នេះ តំបន់នេះក៏ក្លាយជាកន្លែងសក្តិសិទ្ធិសម្រាប់អ្នកភូមិ។ នៅពេលអ្នកភូមិមានជំងឺដង្កាត់ពួកគេបានដាក់សែនឈាម ជ្រូក ឬ មាន់ ជាដង្វាយ អុជធូប ទៀន ហើយធ្វើការបន់ស្រន់នៅកន្លែងនោះ ដើម្បី សុំសេចក្តីសុខសប្បាយ។តំបន់នោះក៏បានក្លាយទៅជា កន្លែងដែលអ្នកស្រុកប្រារព្ធធ្វើពិធី បុ ណ្យសាសនាផ្សេងៗរបស់អ្នកភូមិ។

អ្នកភូមិជំនាន់នោះ គឺជាបុព្វបុរសរបស់ជនជាតិព្នង។ នៅពេលយប់ អ្នកដែលមានបារមីបានយល់សុបិន្តឃើញ ព្រលឹងមក ទាក់ទងជាមួយ ហើយបង្ហាញពីកន្លែងកែវទិព្វ ដែលដុះនៅលើថ្ម ហើយប្រាប់អំពីរបៀប

ដកយក និងប្រមូលកែវទិព្វទាំងនោះ។ បន្ទាប់មក អ្នកភូមិទាំងនេះក៏បាននាំគ្នាទៅដកយកថ្មកែវទិព្វនោះ។ អ្នកខ្លះដាក់ វានៅលើហឹងក្នុងផ្ទះ ចំណែកឯអ្នកខ្លះទៀតដាក់វានៅក្នុងថង់ ដើម្បីទុកជាគ្រឿងសក្ការៈបូជា។ អ្នកភូមិ ដែលមានថ្មកែវទិព្វនោះ តែងតែទទួលបានភ័ព្វសំណាងសព្វបែបយ៉ាង មិនមែនតែចំពោះខ្លួនគេទេ តែបានដល់ក្រុមគ្រួសារ ព្រមទាំងសត្វពាហនៈរបស់ពួកគេផងដែរ។

នៅពេលដែលមានពិធីបុណ្យនៅក្នុងភូមិ អ្នកដែលមានថ្មកែវទិព្វបាននាំយកកែវទាំងនោះមកដាក់នៅកន្លែងសក្តិសិទ្ធ ដើម្បីសែនព្រេនក្នុងភូមិ។ បន្ទាប់ពីបញ្ចប់ពិធីបុណ្យហើយ ពួកគេក៏យកកែវទិព្វរបស់ខ្លួនត្រឡប់ទៅផ្ទះវិញ។ អ្នកភូមិបានដាក់ឈ្មោះកន្លែង ដែលខ្លួនបានយកថ្មកែវទិព្វនោះថាកែវសីម៉ា ដែលស្ថិតនៅក្នុងព្រៃអូរឈ្លូង។ តក្រោយមកទៀត កន្លែងនោះត្រូវបានគេហៅថាស្រុក កែវ សីមា។ បច្ចុប្បន្នព្រៃនេះ ស្ថិតនៅឃុំស្រែព្រះ ស្រុក កែវ សីមា ក្នុងខេត្តមណ្ឌលគីរី។

ក្នុងជំនាន់ប៉ុលពត (ប្រហែល ៤០ឆ្នាំកន្លងទៅ) ថ្មកែវទិព្វទាំងអស់ត្រូវបានរឹបអូសអស់ដូច្នេះហើយរហូតដល់សព្វថ្ងៃ គ្មាននរណាអាចបានឃើញ កែវ សីមា ទៀតទេ។

---ចប់---



# ថ្នាក់ទី ៥ ដល់ថ្នាក់ទី ៦ អនុវិទ្យាល័យ

គោលបំណង

- ត្រឡប់ទៅមើលរឿងនិទាន និងពិធីបុណ្យសាសនាតាមបែបប្រពៃណី ដែលបានបន្សល់ទុក នៅក្នុងភូមិ។
- យល់ដឹងអំពី ធនធាននានា ជាច្រើនប្រភេទផ្សេងៗគ្នានៅតាមតំបន់ជុំវិញ។
- កត់សម្គាល់ និងយល់ដឹងអំពី ការពិត ដែលធនធាននានា កាន់តែកម្រជាងកាលពីមុន។
- កត់សម្គាល់ និងយល់ដឹងអំពី ការពិតនៃការពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់មនុស្ស (ការអភិវឌ្ឍន៍) និងការផ្លាស់ប្តូររបៀបរស់នៅ ដែលពាក់ព័ន្ធជាមួយនឹងការកើនឡើង និងការថយចុះនៃធនធាននានា។

សកម្មភាពទី ១) (ត្រូវការរយៈពេលៈ ប្រហែលមួយម៉ោង)

១. អ្នកសម្របសម្រួលចាប់ផ្តើមនិទានរឿង ដោយនិយាយថា "ខ្ញុំនឹងអានរឿងនិទានមួយដែលមានចំណងជើងថា "កែវទិព្វ" ដែលជារឿងព្រេងរបស់ប្រទេសកម្ពុជានិយាយអំពី កែវអាថ៌កំបាំងមួយប្រភេទ។ ចូរស្តាប់រឿងនិទាន ហើយគិតថា តើថ្មកែវវេទមន្តនេះមានទំនាក់ទំនងទៅនឹងឈ្មោះទីកន្លែងនានា នៅក្នុងតំបន់យ៉ាងដូចម្តេច និងអំពីរបៀប ដែលថ្មកែវវេទមន្ត ភ្ជាប់ទំនាក់ទំនងនឹងជីវិតមនុស្ស"។ បន្ទាប់មកសូមអ្នកសម្របសម្រួលអានរឿងនិទានឲ្យបានលឺៗ។

២. សួរសិស្សថា "នៅក្នុងរឿងនិទាននេះ ហេតុអ្វីបានជាកន្លែងនេះ ត្រូវបានដាក់ឈ្មោះថា កែវសីមា?"

៣. សួរសិស្សថា "តើប្រជាជនរស់នៅក្នុងស្រុក កែវ សីមា ជឿជាក់ថា 'កែវទិព្វ' មានអំណាចអ្វី?"

៤. សួរសិស្សថា "ប្រជាជនដែលរស់នៅក្នុងស្រុក កែវ សី មា ប្រើប្រាស់ 'កែវទិព្វ' នៅក្នុងពិធីបុណ្យសាសនា ដើម្បីបួងសួងសុំសេចក្តីសុខដល់អ្ន ករាល់គ្នា ប៉ុន្តែតើបុណ្យសាសនាប្រភេទណា ដែលត្រូវបានធ្វើឡើងនៅក្នុងភូមិរបស់យើង? " សិ ស្ស អាចពិភាក្សាសំណួរនេះជាក្រុមតូចៗ ហើយធ្វើបទបង្ហាញគំនិតយោបល់របស់ខ្លួនទៅកាន់ក្រុមទាំងមូល។

៥. សួរសិស្សថា "តើមានកន្លែង ឬវត្ថុណាមួយ នៅក្នុងភូមិរបស់យើង ដែលមានរឿងនិទានអាថ៌កំបាំងដំណាលតៗគ្នាដែរឬទេ"?

៦. ប្រាប់សិស្សថា "កាលពីមុន 'កែវទិព្វ' ត្រូវបានរកឃើញនៅក្នុងស្រុក កែវ សីមា ប៉ុន្តែគេនិយាយថា កែវទិព្វនេះលែងឃើញមានហើយ"។ បន្ទាប់មក សួរថា "តើប្រភេទធនធានអ្វីខ្លះ ដែលយើងមាននៅក្នុងភូមិរបស់យើង?" ចូរសរសេរធនធាននានា ដែលសិស្សបានលើកឡើងនៅលើក្តារខៀន។

៧. សួរសិស្សថា "តើមានធនធានណា ដែលកាលពីមុនត្រូវបានរកឃើញនៅទីនេះ ប៉ុន្តែបច្ចុប្បន្នប្រែជាកម្រមាន ឬក៏បាត់បង់អស់ដែរឬទេ? ប្រសិនបើមានធនធានបែបនេះ ហេតុអ្វីបានជាអ្នកគិតថា វាកម្រ

មាន ឬក៏បានបាត់បង់អស់ទៅហើយ?" ចូរសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។

៨. បន្ទាប់មកសួរសិស្សថា "តើអ្នកគិតថានឹងមានអ្វីកើតឡើង ប្រសិនបើធនធានទាំងនោះបានបាត់បង់ទៅ? ចូរសរសេរគំនិតយោបល់របស់សិស្សនៅលើក្តារខៀន។

៩. បន្ទាប់មកសួរសិស្សថា "តើប្អូនគិតថា យើងអាចធ្វើអ្វីបានខ្លះ ដើម្បីការពារកុំឲ្យធនធានទាំងនោះ ហិនហោចកាន់តែខ្លាំងជាងពេលបច្ចុប្បន្ននេះដែរឬទេ?" ចូរសរសេរគំនិតយោបល់របស់សិស្សនៅលើក្តារខៀន។

១០. ចូរសង្ខេបសកម្មភាព ដោយបញ្ជាក់ប្រភេទខាងក្រោម ជាមួយសិស្ស "មានរឿងរ៉ាវ និង រឿងនិទាន ផ្សេងៗ បានបន្សល់ទុកពីមួយជំនាន់ទៅមួយជំនាន់នៅក្នុងភូមិនេះ"។ "មានទំនៀមទន្លាប់ផ្សេងៗ ដែលជាប់ពាក់ព័ន្ធនឹងធនធានធម្មជាតិ"។ "មានការជាប់ទាក់ទងគ្នា រវាងជីវិតប្រចាំថ្ងៃរបស់មនុស្ស និងការហិនហោចធនធានធម្មជាតិនានា"។ "មានរឿងរ៉ាវដែលយើង អាចធ្វើវិធានការ ដែលយើងត្រូវប្រកាន់យកដើម្បីការពារធនធានទាំងនេះ"។

សកម្មភាពទី ២) បទសម្ភាសន៍ (ត្រូវការរយៈពេល៖ សកម្មភាពមុនបទសម្ភាសន៍ + មួយម៉ោង

១. ស្រាវជ្រាវប្រភពដើមនៃឈ្មោះភូមិ ឬ ស្រុក
២. ស្វែករកឲ្យឃើញថា នៅពេលណា ដោយសារមូលហេតុអ្វី ហើយវិធីប្រារព្ធពិធីបុណ្យសាសនា ដែលត្រូវធ្វើនៅក្នុងភូមិ។
៣. អនុវត្តជំហានទី ១ ដល់ទី ៣ ពីសកម្មភាពទី ១)
៤. ឲ្យសិស្សចែកជាក្រុមតូចៗ បង្ហាញលទ្ធផលរបស់ខ្លួនសម្រាប់ជំហានទី ១ និងទី ២
៥. អនុវត្តជំហានទី ៧ ដល់ទី ១០ ពីសកម្មភាពទី ១)

សកម្មភាពទី ៣) លំដាប់ពេលវេលាសម្រាប់ពេលអនាគត (ត្រូវការរយៈពេល៖ ប្រហែល ៤០នាទី)

១. អនុវត្តជំហានទី ១ ដល់ទី ៨ ពីសកម្មភាពទី ១)

២. ប្រាប់សិស្សថា "ចូរគិតអំពីអនាគតនៃ xx (ធនធានជាក់លាក់មួយ) ដែលកម្រមាននៅក្នុងតំបន់ជុំវិញយើង ប្រៀបធៀបជាមួយកាលពីពេលមុន"។

៣. សួរសិស្សថា "x x បានចាប់ផ្តើមហិនហោច បើប្រៀបធៀបជាមួយកាលពីមុន ប៉ុន្តែតើអ្នកគិត

ថានឹងមានអ្វីកើតឡើងចំពោះ xx នាពេលអនាគត? តើអ្នកគិតថាវានឹងមានការកើនឡើង ឬថយចុះចាប់ពីពេលឥលូវនេះតទៅ?˝

៤. គូរទម្រង់លម្អិតនៃដ្យាក្រាម កំណត់ពេលវេលាសម្រាប់ពេលអនាគត (មើលសកម្មភាពទី ៣) រឿងនិទាន ទីទុយ និង ក្តាន់) ជាមួយ ˝អតីតកាល˝ នៅខាងឆ្វេង ។

៥. នៅលើដ្យាក្រាម ចូរសរសេរអំពី អ្វីដែលបានកើតឡើងចាប់តាំងពីអតីតកាល រហូតដល់ពេលបច្ចុប្បន្ន ។

៦. សួរសិស្សថា តើរឿងអ្វីខ្លះដែលអាចកើតឡើង ដើម្បីសរសេរចូលក្នុងបន្ទាត់វេលាចាប់ពី ˝បច្ចុប្បន្ន˝ ដល់ ˝អនាគត ខ្ញុំមិនចង់ឃើញ – ធនធាននានាបាត់បង់ឡើយ˝ ហើយចូរសរសេរចម្លើយទាំងនោះនៅលើដ្យាក្រាម។

៧. បន្ទាប់មក ឲ្យសិស្សផ្តល់គំនិតយោបល់របស់ខ្លួនថា តើយើងអាចធ្វើអ្វីបានខ្លះ ឬត្រូវមានអ្វីខ្លះកើតឡើង ដើម្បីឲ្យបន្ទាត់ពេលវេលា ˝បច្ចុប្បន្ន˝ ដល់ ˝អនាគត ខ្ញុំចង់ឃើញ – ធនធានសម្បូរបែប˝ ហើយសរសេរគំនិតយោបល់ទាំងនោះទៅក្នុងដ្យាក្រាម។

៨. ពិនិត្យមើលទូទៅលើដ្យាក្រាម ដែលបានបំពេញ ហើយសង្ខេបសកម្មភាព ដោយនិយាយអំពីអ្វីដែលបានកើតឡើង (ចាប់ពីអតីតកាលដល់បច្ចុប្បន្ន) នាំឲ្យមានស្ថានភាពដូចពេលបច្ចុប្បន្ន និងអ្វីដែលយើងត្រូវតែធ្វើ ឬអ្វីដែលយើងចាំបាច់ត្រូវសម្រេចឲ្យបាន ដើម្បីនាំមកនូវអនាគត ដែលពោរពេញទៅដោយធនធានសម្បូរបែបនៅក្នុងភូមិ ឬតំបន់នេះ។



# រឿង ផាដែង
# និង ព្រះនាងអាយ

(Pha-Daeng and Nang Ai)



*ចូរអានអានរឿងនិទានដូចខាងក្រោម ហើយគិតអំពី សណ្ឋានដី និង ទឹក*

*រឿងនេះត្រូវបាននិទានប្រាប់ដោយលោក* ថាវ៉ុន ម៉ាណូស៊ីន (Thawon Manosin) នៅឃុំ ហ៊ួអាយសំផាដ (Huay Sam Phad) ស្រុក ប្រាចក្រស៊ីនឡាផាកន (Prachaksinlapakhom) ខេត្ត ឧដនថានី (Udon Thani) នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០១៤។ រឿងនេះនិយាយអំពី ការកកើតឡើងនូវបឹង ណុង ហាន (Nong Han) ក្នុងខេត្ត ឧដនថានី ព្រមទាំងសំដៅ ដល់ឈ្មោះទីកន្លែង ដែលមានស្រាប់ជាច្រើននៅក្នុងតំបន់នោះ។ សាច់សត្វកំប្រុកសនៅក្នុងរឿងនិទា ននេះគឺជានិមិត្តរូបនៃអំបិល ឬ ប៉ូតាស្យូម/ប៉ូតាស។ ប្រសិនបើមនុស្សជីករុករក និងប្រើប្រាស់រ៉ែហ្លួសកម្រិត ដីនឹងបាក់ស្រុតចុះ ដូចគ្នាបេះបិទទៅនឹងប្រជាជន ដែលរស់នៅ គីតាណាខន (Khita Nakhon) រួមទាំងព្រះនាង ណាំងអាយ (Nang Ai) ផងដែរនោះ ដែលបានដឹងថា ទីក្រុងរបស់ខ្លួនបានស្រុតចុះ នៅពេលដែលពួកគេហូបសាច់កំប្រុកច្រើនពេក។

ថាវ ផាំងគី (Thaw Phangkhi) ដែលជាបុត្រាស្តេចនាគ។ ផាំងគី បានប្រែកាឡាខ្លួនទៅជាសត្វកំប្រុក ដើម្បីស្វែងរកនាង ណាំងអាយ នេះក៏ដោយសារតែ ផាំងគី បានកើតជាមនុស្សគ កាលពីជាតិមុន។ នាង អាយ កាលពីជាតិមុនឈ្មោះនាង អុងខាំ (Ongkham) គឺជាកូនស្រីរបស់បុរសអ្នកមានម្នាក់។ នាងមានសម្រស់ស្អាតផូរផង់ណាស់ ប៉ុន្តែនាងមិនស្រលាញ់បុរសណាម្នាក់ឡើយ។ ឪពុកម្តាយរបស់នាង ស្រលាញ់ចូលចិត្តបុរសគនេះ ដោយសារតែគាត់ គឺជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ ហើយក៏បានសុំឲ្យបុរសគនោះ រៀបការជាមួយនាង អុងខាំ។ ប៉ុន្តែបុរសគនោះមិនពេញចិត្តនឹងនាងទេ។ បុរសនោះមិនចាប់អារម្មណ៍នឹងនាងឡើយ ហើយក៏មិនមាន សម្ព័ន្ធភាពស្នេហាជាមួយនឹងនាងដែរ។ ពួកគេគ្រាន់តែរស់នៅជាមួយគ្នា និងធ្វើពុតជាប្តីប្រពន្ធតែប៉ុណ្ណោះ។

ច្រើនឆ្នាំកន្លងផុតទៅ បុរសគបានក្លាយខ្លួនជាអ្នកមាន និងមានបំណងចង់ត្រឡប់ទៅរស់នៅក្នុងផ្ទះចាស់ជាមួយឪពុកម្តាយរបស់ខ្លួនវិញ។ គាត់បានកុហកនាង អុងខាំ ថា គាត់នឹងទៅធ្វើដំណើរទៅដោយខ្លួនឯង។ ប៉ុន្តែនាង អុងខាំ បាននិយាយថា នាងក៏ចង់ទៅជាមួយប្តីដែរ ដើម្បីជួបម្តាយរបស់គាត់ជាមួយគ្នា។ ប៉ុន្តែប្តីរបស់នាងមិនចង់ឲ្យនាងទៅជាមួយគាត់ទេ ដោយសារតែគាត់មានបំណងចង់គេចចេញពីនាង។ ពួកគេទាំងពីរ បានធ្វើដំណើរជាមួយគ្នា ហើយពេលល្ងាចពួកគេបានឈប់សម្រាក នៅក្រោមដើមល្វាមួយនៅក្បែរមាត់ទន្លេ។

បុរសជាប្តីបានឡើងដើមល្វា ដើម្បីបេះផ្លែឈើហូប ប៉ុន្តែគាត់មិនបានបោះចុះក្រោមឲ្យនាង អុងខាំ សូម្បីតែមួយផ្លែឡើយ។ គាត់មិនបានបង្ហាញការចាប់អារម្មណ៍អ្វី មកលើប្រពន្ធខ្លួនទាល់តែសោះ។ នាងជា ប្រពន្ធចាប់ផ្តើមឃ្លាន ក៏រើសផ្លែល្វា ដែលជ្រុះលើដីយកមកហូបទៅ។ ចំណែកបុរសជាប្តី មិនបានចុះមកដីវិញឡើយ ប៉ុន្តែគាត់បានដេកនៅលើដើមឈើ ខណៈពេលដែលនាង អុងខាំ ដេកនៅក្រោមដើមឈើ។ នៅពេលដែលបុរសជាប្តីឃើញនាង អុងខាំ ដេកលង់លក់ហើយ គាត់ក៏ចុះមកដី ហើយរត់គេចខ្លួនបាត់ទៅ ដោយបន្សល់ទុកឲ្យប្រពន្ធខ្លួននៅតែឯកឯង។

សំណាងល្អដែលមិនមានសត្វខ្លាមកស៊ីនាង អុងខាំ។ នាងភ្ញាក់ឡើងមិនឃើញប្តីរបស់ខ្លួន។ រួចនាងក៏បានដើរចេញពីព្រៃ ប៉ុន្តែមិនដឹងថាត្រូវទៅតាមផ្លូវណា។ បន្ទាប់មកនាងបានជួបនឹងព្រានម្នាក់ ហើយសុំឲ្យព្រាននោះជូននាងទៅកាន់ទន្លេ។ បន្ទាប់មកព្រានបានប្រាប់ឲ្យនាងហែលឆ្លងទន្លេ ដើម្បីបានទៅដល់ផ្ទះប្តីរបស់ខ្លួននៅត្រើយម្ខាងទៀត ហើយក៏បានចាកចេញទៅ។ ខណៈពេលដែលកំពុងហែលឆ្លងទន្លេនាង អុងខាំ ក៏បានលង់ទឹកស្លាប់។

រាងកាយរបស់នាង បានលិចចូលទៅក្នុងទន្លេបាត់ទៅ។ នៅពេលជិតស្លាប់ នាងបានប្រាថ្នាថា ទៅជាតិមុខសូមឲ្យប្តីរបស់នាងស្រលាញ់នាង ហើយប្រាថ្នាថែមទៀតថា សូមឲ្យនាងមានសម្រស់កាន់តែស្អាតជាងនេះ ព្រមទាំងសូមឲ្យប្តីរបស់ខ្លួន ឈ្លក់វង្វេងនឹងសម្រស់នាងកាន់តែខ្លាំង។

ជីវិតរបស់នាង អុងខាំ ក៏បានបញ្ចប់នៅពេលនោះទៅ។ បន្ទាប់មក នាងបានចាប់ជាតិជាថ្មីនៅ គីតាណាខនជាព្រះនាងដោយមានឈ្មោះថាព្រះនាង អាយខាំ ឬ ព្រះនាង អាយ ចំណែកបុរសជាព្រាន និងបុរសគ ក៏បានចាប់ជាតិជាថ្មី ដែលបុរសព្រានមានឈ្មោះថា ថាវ ផាដែង (Thaw Phadaeng) ហើយបុរសគនោះឈ្មោះ ថាវ ផាំងគី (Thaw Phangkhi)។ ព្រះនាង អាយ គឺជាបុត្រីរបស់ស្តេច គីតាណាខន ទ្រង់មានប្អូនប្រុសមួយអង្គទៀតនៅឈៀងហៀន (Chiang Hien)។ សម្រស់របស់ព្រះនាង អាយ មានភាពល្បីរន្ទឺ នៅតាមកន្លែងនានាជាច្រើនរួមទាំងនៅ ផាផុង (Pha Phong) ជាទីកន្លែងដែល ផាដែង រស់នៅផងដែរ។ ផាដែង បានធ្វើដំណើរទៅកាន់ គីតាណាខន ហើយក៏បានឮគេនិយាយថាព្រះនាង អាយ មានសម្រស់ស្រស់ស្អាតណាស់។ ហេតុដូច្នេះហើយ ផាដែង ក៏បានលបចូលក្នុងព្រះរាជដំណាក់របស់ព្រះនាង អាយ ផ្តោះផ្តងវាចា ហើយក៏បានរួមមេត្រីជាមួយព្រះនាងទៅ។ សម្រស់របស់ព្រះនាង អាយ ក៏បានល្បីដល់ឋានក្រោមផងដែរ។ ថាវ ផាំងគី បានឮថាព្រះនាង អាយ មានសម្រស់ស្រស់ស្អាត ហើយក៏បានកាឡាខ្លួនទៅជាមនុស្ស រួចចូលទៅក្បែរព្រះនាង ប៉ុន្តែមិនអាចចូលទៅជិតព្រះនាងបានឡើយ ដូចនេះក៏ត្រឡប់ទៅឋានរបស់ខ្លួនវិញ។ ហើយត្រឡប់មកជួបព្រះនាងម្តងទៀត ប៉ុន្តែគេនៅតែមិនមានឱកាសនិយាយជាមួយព្រះនាងដដែល។

នៅ គីតាណាខន ប្រជារាស្ត្របានប្រារព្ធពិធីបុណ្យ បាឯក ហ្វាកូ ហ្វុងជូ បាងហ្វៃ (Baek Fa Ko Fon Jud Bang Fai) ដើម្បីសុំទឹកភ្លៀងពីលើមេឃ នៅក្នុងខែ ៥ ឬខែ៦ ជារៀងរាល់ឆ្នាំ។ ពិធីបុណ្យនេះ ត្រូវបានប្រារព្ធរួមគ្នាជាមួយនឹងការប្រកួត បាងហ្វៃ (bang fai) ឬ បាញ់កាំជ្រួច។ ស្តេច គីតាណាខន បានផ្ញើសារអញ្ជើញទៅកាន់ទីកន្លែងផ្សេងៗគ្នា រួមទាំង ផាផុង និង ឈៀងហៀន ដោយព្រះអង្គបានមានព្រះរាជបន្ទូលថា "ប្រសិនបើ ឈៀងហៀន ឈ្នះ យើងនឹងប្រគល់នគរឲ្យ ប្រសិនបើ ថាវ ផាដែង ដែលមកពី ផាផុង ឈ្នះយើងនឹងលើកព្រះនាង អាយ ឲ្យជារង្វាន់"។ នៅក្នុងថ្ងៃពិធីបុណ្យ និងថ្ងៃប្រកួតនេះ មានប្រជារាស្ត្រមកចូលរួមជាច្រើន។ ដំណឹងនៃការប្រកួត បាងហ្វៃ នេះក៏បានលេចឮដល់ឋានក្រោមផងដែរ។ ផាំងគី ក៏បានមកកាន់ឋានមនុស្សលោក ហើយកាឡាខ្លួនទៅជាមនុស្ស ដើម្បីទៅជិតព្រះនាង អាយ ប៉ុន្តែនៅតែមិនអាចនិយាយជាមួយព្រះនាងបានដដែល។

ការប្រកួត បាងហ្វៃ បានចាប់ផ្តើម។ ការប្រកួតនេះមានរយៈពេលប្រាំពីរថ្ងៃប្រាំពីរយប់។ ប៉ុន្តែកាំជ្រួចរបស់ ផាដែង បាញ់មិនបានខ្ពស់បំផុតឡើយ។ គាត់បានប្រកួតចាញ់ស្តេច ឈៀងហៀន ហើយមិនអាចយកព្រះនាងអាយមកធ្វើជាប្រពន្ធរបស់ខ្លួនឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ផាដែង នៅតែបន្តជិះសេះដែលមានឈ្មោះថា ម៉ាប៊ុសំ (Ma Bug Sam) មកលេងព្រះនាង អាយ យ៉ាងទៀងទាត់។ ផាំងគី មិនអាចទទួលយករឿងនេះបានទេ ហើយបានរៀបចំផែនការជាច្រើន ប៉ុន្តែទទួលបរាជ័យរហូត។ ដូច្នេះគាត់ក៏បានកាឡាខ្លួនទៅជាសត្វកំប្រុកសឡើងទៅយ៉ខាងមុខព្រះរាជដំណាក់របស់ព្រះនាង អាយ ហើយលេងនៅទីនោះ ដើម្បីឲ្យព្រះនាងមើលឃើញខ្លួន។ ព្រះនាង អាយ ចង់ចាប់សត្វកំប្រុកនេះ ហើយក៏បានបញ្ជាទាសាទាសីឲ្យហៅព្រាន មកចាប់សត្វកំប្រុកនេះឲ្យខ្លួន។ ព្រានក៏បានមកនៅក្បែរនោះ ហើយចាប់ផ្តើមតាមចាប់សត្វកំប្រុកនេះ។ ផ្ទះរបស់ព្រានមានទីតាំងនៅក្នុងភូមិ កុងផាន (Kong Phan) បច្ចុប្បន្ននេះ។ ព្រានថែមទាំងបានស្នើរសុំឲ្យអ្នកភូមិ មកជួយចាប់សត្វកំប្រុកនេះផងដែរ។

ដំបូងសត្វកំប្រុកសរត់គេចចូលក្នុង សួនមន (suan mon) ដែលបច្ចុប្បន្នស្ថិតនៅក្នុងភូមិ សួនមន (Suan Mon) ហើយរត់កាត់ព្រៃ រត់ឡើងដើមច័ន្ទលើជម្រាលភ្នំ អុមជែន (Um Jan) ដែលបច្ចុប្បន្នស្ថិតនៅក្នុងភូមិ អុមជែន (Um Jan)។ ទោះបីជាយ៉ាងណាក៏ដោយ ព្រានមិនអាចបាញ់សត្វកំប្រុកពីជម្រាលភ្នំ អុមជែន បានឡើយ។

បន្ទាប់មកទៀតសត្វកំប្រុក ក៏រត់ចេញពីជម្រាលភ្នំ អុមដែន ទៅជម្រាលភ្នំ ផុនថុង (Phon Thong) ដែលបច្ចុប្បន្ន ស្ថិតនៅក្នុងភូមិ ផុនថុង (Phon Thong) ប៉ុន្តែព្រាននៅតែមិនអាចបាញ់សត្វកំប្រុកនេះបានដដែល។ ខ្សែធ្នូរបស់ព្រានក៏បាន ដាច់។ ព្រានស្វែងរកខ្សែថ្មីមួយទៀត ប៉ុន្តែមិនអាចរកបានសូម្បីមួយខ្សែឡើយ។ បន្ទាប់មក ព្រានក៏រកខ្សែបានមួយនៅភូមិ ផុនថុង ហើយនាំយកទៅភូមិ កូនសៃ (Khon Sai) (ភូមិយកខ្សែ) ហើយបាញ់សត្វកំប្រុក។ ទោះជាយ៉ាងណាក៏ដោយ ព្រាននៅតែមិនអាចចាប់សត្វនេះបានដដែល។ ធ្នូក៏បានបញ្ចេញសំឡេងយ៉ាងខ្លាំង "ភុក" ។ ដូច្នេះហើយទើបតំបន់នេះត្រូវបានគេហៅថាភូមិ មួងភុក (Muang Puk)។ សត្វកំប្រុក ឬ ផាំងគី បញ្ជាឲ្យបរិវាររបស់ខ្លួនជាសត្វបក្សី និងពស់ ទៅបន្លាចព្រាន ប៉ុន្តែព្រានមិនមានការភ័យខ្លាចឡើយ។ ព្រានក៏បានបាញ់សម្លាប់សត្វបក្សី និងពស់ទាំងអស់នោះ។

កំប្រុកសរត់គេចពីជម្រាលភ្នំ ផុងថុង ហើយរត់ចូលក្នុងរូងដើមឈើធំមួយនៅក្នុងព្រៃ។ ព្រានគិតថា សត្វកំប្រុកនោះប្រាកដជា នៅក្នុងរូងដើមឈើនោះ ហើយក៏បាញ់វាជាមួយអ្នកភូមិជាច្រើននាក់ ប៉ុន្តែនៅតែមិនអាចបាញ់សម្លាប់វាបានទាល់តែសោះ។ សត្វកំប្រុករត់គេចចេញទៅឆ្ងាយ ព្រានក៏រត់ដេញតាម។ លើកនេះ ព្រានសាកសួរភិក្ខុសង្ឃមានឈ្មោះថា សាំងសំ (Siang Som) ដែលបានលាចាកពីសិក្ខាបទ និងជាអ្នកដែលទើបតែបានឃើញសត្វកំប្រុកអម្បាញ់មិញនេះ។ សាំងសំ បានទទួលរង្វាន់ ឬ ហៅថា ង្វៀន (nguen) ហើយប្រាប់ព្រាន និងអ្នកភូមិឲ្យធ្វើដំណើរទៅកាន់ភូមិ ដុងង្វៀន (Don Nguen)។ ព្រាន និងអ្នកភូមិដេញតាមសត្វកំប្រុកដល់ដើមល្វាមួយ ហើយព្រានក៏បានបាញ់សត្វកំប្រុកនោះ ធ្លាក់មកលើដីស្លាប់បាត់ទៅ។

ព្រាន និងអ្នកស្រុកបានត្រឡប់មកទីកន្លែង ដែលបច្ចុប្បន្ននេះហៅថាភូមិ ឈៀងហ៊ាវ (Chaing Haew) ហើយសាំងសំ ក៏បានចៀរពន្លះសាច់កំប្រុកនោះ។ ប៉ុន្តែនៅពេលកាត់ជាចំណែកតូចៗ សាច់កំប្រុកនេះមានចំនួនច្រើនរហូតដល់ដាក់ពេញបានមួយពាន់រទេះឯណោះ។ សាច់កំប្រុកទាំងនេះត្រូវបានចែកឲ្យអ្នកភូមិនៅ គីតាណាខន លើកលែងតែស្ត្រីមេម៉ាយដែលមិនមានប្តី ឬកូនចេញមកជួយព្រានបាញ់សត្វកំប្រុកនេះ ទើបមិនមានចំណែក។ នៅពេលល្ងាច អ្នកភូមិបានជួបជុំគ្នាហូបសាច់កំប្រុក ហើយក្លិនឈ្ងុយក៏ជះដល់ឋានក្រោម។

ដំណឹងនេះ ក៏បានលេចឮទៅដល់នគររបស់ស្តេចនាគថា បុត្រារបស់ទ្រង់ត្រូវបានបាញ់សម្លាប់។ ស្តេចនាគមានការខឹងក្រោធជាខ្លាំង ក៏បញ្ជាឲ្យកងសេនារបស់ខ្លួនទៅកម្ទេច គីតាណាខន ។ កន្លែងណាក៏ដោយឲ្យតែទាហ៊ានបានឃើញមានសាច់កំប្រុកនៅលើដី កន្លែងនោះត្រូវតែកំទេចឲ្យលិចបាត់ទៅក្នុងដីទាំងអស់។

ផាដែង បានធ្វើដំណើរទៅកាន់ គីតាណាខន នៅពេលសោយអាហារពេលយប់ ដើម្បីស្វែងរកព្រះនាង អាយ ហើយក៏បានធំក្លិនម្ហូបអាហារ។ ពេលដែលខ្លួនចូលក្នុងបន្ទប់របស់ព្រះនាង អាយ ព្រះនាងកំពុងតែហូបអាហារ ហើយបាននិយាយទៅកាន់ ផាដែង ថា "ខ្ញុំហូប ឡាបក្រារុ larb krarog (ញាំសាច់កំប្រុកចិញ្ច្រាំ) ដែលបានមកពីសត្វកំប្រុក ដែលមានខ្សែកមាស"។



ផាដែង ក៏សួរថា តើព្រះនាងមិនខ្លាច ទឹកដីរបស់ព្រះនាងបាក់ស្រុតទៅក្រោមដីបាត់ទេឬ?″ ពេលនិយាយដូច្នេះក៏មានសូរសម្លេងលាន់ឮរំពងយ៉ាងខ្លាំងពីទីក្រុង។ ផាដែង ប្រាប់ព្រះនាង អាយ ឲ្យប្រញាប់ប្រញាល់រត់ឡើងជិះលើខ្នងសេះរបស់ខ្លួនឈ្មោះ ម៉ា ប៊ូសំ។ ទីក្រុងចាប់ផ្តើមរងការបំផ្លិចបំផ្លាញជាបណ្តើរៗ។ ព្រះនាង អាយ បានប្រមែប្រមូលវត្ថុមានតម្លៃរបស់ខ្លួនដូចជា ចិញ្ចៀនមួយវង់ ខ្សែកមួយខ្សែ និងវត្ថុផ្សេងៗទៀតដូចជា ឃ្នោះមួយ ស្គរមួយ និងមាសដាក់តាមខ្លួន។

វត្ថុទាំងអស់នេះធ្វើឲ្យ សេះ ម៉ាប៊ូសំ មានការពិបាករត់ផាយទៅមុខ។ ស្តេចនាគ និងកងពលទាហានរបស់ខ្លួនកំពុងតែខិតជិតមកដល់ហើយ ដោយពុះជ្រែកព្រះធរណី។ សេះ ម៉ាប៊ូសំ ផាយមកដល់ទន្លេមួយ។ ផាដែងបានប្រាប់ឲ្យព្រះនាង អាយ បោះវត្ថុមានតម្លៃ ដែលព្រះនាងដាក់តាមខ្លួន ចោលចូលក្នុងទន្លេឲ្យអស់ ដោយសារតែវាធ្ងន់ពេក។



ដូច្នោះហើយព្រះនាងក៏បានបោះចោលឃ្មោះ បន្ទាប់មក ស្គរ ចិញ្ចៀន និងរបស់មា នតម្លៃទាំងអស់សល់តែខ្លួនព្រះនាងប៉ុណ្ណោះ។ សេះ ម៉ាប៊ូសំ ព្យាយាមផាយផ្លោះរំលងកំណាត់ឈើដែលបង្ខាំងផ្លូវប៉ុន្តែមិនអាចផ្លោះរំលងបានទេ ដោយសារតែស្តេចនាគបានកាឡាខ្លួនជាកំណាត់ឈើនោះ។ ផាដែង គិតរកមធ្យោបាយដើម្បីជួយសង្គ្រោះព្រះនាងអាយ។ គាត់ក៏ដាក់ព្រះនាងនៅលើដីដោយទុកនាងចោលហើយចាំមកយកព្រះនាងនៅពេលក្រោយ។ ប៉ុន្តែ បន្ទាប់ពីទុកព្រះនាងចោលលើដីភ្លាម ព្រះនាងក៏បានលិចទៅក្នុងទឹក។ ផាដែង និងសេះ ម៉ាប៊ូសំ ក៏បានវិលត្រឡប់ទៅកាន់ទីក្រុងវិញ ហើយបានត្រឹមតែឃើញបឹង ដែលពោរពេញទៅដោយទឹកតែប៉ុណ្ណោះ។ នេះហើយគឺជារឿងប្រវត្តិរបស់បឹង ណុងហាន (Nong Han)។

---ចប់---

# ថ្នាក់ទី ៥ ដល់ថ្នាក់ទី៦ អនុវិទ្យាល័យ

**គោលបំណង**

- ដឹងអំពីលក្ខណៈសណ្ឋានដីនៃតំបន់ ដែលសិស្សរស់នៅ
- យល់ដឹងអំពីទំនាក់ទំនងរវាងសណ្ឋានដីនៃតំបន់នោះ និងជីវិតរបស់ប្រជាជន ដែលរស់នៅទីនោះ
- បង្កើតអារម្មណ៍សំាជាមួយនឹងរុក្ខជាតិ និងសត្វក្នុងស្រុក ហើយបណ្តុះក្តីស្រលាញ់ចំពោះ រុក្ខជាតិ និងសត្វទាំងនោះ ព្រមទាំងអារម្មណ៍ចង់ថែរក្សាពួកវាឲ្យបានល្អ។

សកម្មភាព (ត្រូវការរយៈពេល៖ ៣០ ទៅ ៤០នាទី)

១. អ្នកសម្របសម្រួលសួរសំណួរទៅកាន់ក្រុមទាំងមូលថា "តើអ្នកស្គាល់បឹង ណុង ហាន (ឬ ល ក្ខណៈសណ្ឋានដីផ្សេងទៀត ដែលត្រូវលើកយកមកពិភាក្សា នៅក្នុងសកម្មភាពនេះដែរឬទេ? តើអ្នកធ្លាប់ទៅកាន់ទីនោះដែរឬទេ? តើជាប្រភេទទីកន្លែងអ្វីខ្លះ?"។

២. អ្នកសម្របសម្រួលចាប់ផ្តើមនិទានរឿងថា "ខ្ញុំនឹងអានរឿងនិទានអំពីបឹង ណុង ហានជូនអ្នកស្តាប់ឥលូវនេះ សូមស្តាប់ដោយយកចិត្តទុកដាក់ ដើម្បីស្វែងយល់ថាតើបឹង ណុង ហាន ត្រូវបានកើតឡើងដោយរបៀបណា" បន្ទាប់មកអ្នកសម្របសម្រួលអានរឿងនិទានឲ្យឮៗ។

៣. សួរសិស្សថា "នៅក្នុងរឿងនិទាននេះ ហេតុអ្វីបានជាដីលិចបាត់ ហើយក្លាយជាបឹងធំ?"។

៤. សួរសិស្សថា "តើមានរុក្ខជាតិ និងសត្វអ្វីខ្លះនៅក្នុងសាច់រឿងនេះ?" ចូរសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន។ ដូច្នេះ សិស្សទាំងអស់នឹងដឹងថាមានរុក្ខជាតិ និងសត្វអ្វីខ្លះ នៅក្នុងសាច់រឿងនេះ។ ចំពោះរុក្ខជាតិ និងសត្វ ដែលសិស្សមិនបានលើកឡើង អ្នកសម្របសម្រួលអាចសរសេរឈ្មោះទាំងនេះនៅលើ ក្តា រខៀន ខណៈពេលដែលកំពុងនិទានរឿងនេះ ដោយនិយាយថា "ខ្ញុំគិតថា ... មាននៅក្នុងសាច់រឿង មិនអញ្ចឹង?"។

៥. សួរសិស្សថា "តើមានអ្នកណាខ្លះ ធ្លាប់បានឃើញបាតុភូតដីស្រុតចុះជុំវិញភូមិនៅកន្លែងណាមួយឬទេ?"។

៦. សួរសិស្សថា "តើអ្នកឃើញមានរុក្ខជាតិ និងសត្វណាខ្លះនៅក្នុងរឿងនិទាននេះ នៅតាមតំបន់ជុំវិញភូមិដែរឬទេ?" ចូរសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន (ឬគូសរង្វង់ចម្លើយពាក់ព័ន្ធដែលផ្តល់ជូននៅក្នុងជំហានទី ៤)។

៧. សួរសិស្សថា "តើមានឈ្មោះកន្លែងណាខ្លះក្នុងភូមិរបស់អ្នក មានការជាប់ទាក់ទងជាមួយ នឹងរឿងនិទាន ឬរឿងព្រេងដែរឬទេ? តើវាជាប្រភេទរឿងអ្វី? តើមានរុក្ខជាតិ និងសត្វអ្វីខ្លះនៅក្នុងសាច់រឿងនេះ?" ឲ្យសិស្សធ្វើបទបង្ហាញចម្លើយរបស់ខ្លួន។

៨. សង្ខេបសកម្មភាព ដោយបញ្ជាក់ប្រភេទអំណះអំណាងជាមួយសិស្ស ដូចខាងក្រោម "មានកន្លែងនានានៅក្នុងតំបន់ ដែលមានសណ្ឋានដីជាក់លាក់ដូច្នេះ" "រុក្ខជាតិ និងសត្វមួយចំនួនធំកំពុងរស់នៅជាមួយប្រជាជន ដែលរស់នៅក្នុងភូមិ និងតំបន់នេះ។

# ថ្នាក់ទី ៥ ដល់ថ្នាក់ទី ៦ បឋមសិក្សា

**គោលបំណង**

- ដឹងអំពីលក្ខណៈពិសេសនៃសណ្ឋានដីនៃតំបន់នេះ។
- យល់ដឹងអំពីទំនាក់ទំនងរវាងទីតាំងភូមិសាស្ត្រនៃតំបន់នេះ និងជីវិតរបស់ប្រជាជន។
- យល់ដឹងថាមានករណីណាខ្លះ ដែលប្រពៃណីក្នុងស្រុកបានបន្សល់ទុក នៅក្នុងតំបន់មានជាប់ទំនាក់ទំនងជាមួយបាតុភូតធម្មជាតិ។
- ផ្តល់ជាគន្លឹះក្នុងការគិតអំពី បញ្ហាបរិស្ថាននៅក្នុងតំបន់។

សកម្មភាពទី ១) (ត្រូវការរយៈពេល៖ ប្រហែលមួយម៉ោង)

១. ជាការចាប់ផ្តើមនៃរឿងនិទាននេះ អ្នកសម្របសម្រួលនិយាយថា "ខ្ញុំនឹងអានរឿងនិទានអំពីបឹងណុងហាន ជូនអ្នកស្តាប់ឥលូវនេះ សូមស្តាប់ដោយយកចិត្តទុកដាក់ ដើម្បីស្វែងយល់ថាតើបឹង ណុង ហាន ត្រូវបានកើតឡើងដោយរបៀបណា" បន្ទាប់មក អ្នកសម្របសម្រួលអានរឿងនិទានឲ្យបានឮៗ។

២. សួរសិស្សថា "តើមានឈ្មោះកន្លែងណាខ្លះ នៅក្នុងភូមិរបស់អ្នក ដែលជាប់ពាក់ព័ន្ធនឹងរឿងព្រេង ឬរឿងនិទាននេះដែរឬទេ? តើកន្លែងនោះមានឈ្មោះអ្វីខ្លះ? សូមឲ្យសិស្សផ្តល់ចម្លើយរបស់ខ្លួន។

៣. សួរសិស្សថា "តើមានអ្នកណាខ្លះបានដឹងអំពី បាតុភូតនៃការស្រុតដីនេះកើតឡើងដោយរបៀណាដែរឬទេ? ប្រសិនបើមានបាតុភូតនេះ កើតឡើងនៅជុំវិញភូមិរបស់អ្នកមែន តើអ្នកដឹងទេថា វាបណ្តាលមកពីអ្វី? សូមឲ្យសិស្សផ្តល់ចម្លើយរបស់ខ្លួន។

៤. សួរសិស្សថា "តើអ្នកមានដឹងទេថា អំបិល ដែលជាធម្មតាអ្នកប្រើប្រាស់ជាមួយម្ហូបអាហារមានប្រភពមកពីណា? តើអ្នកដឹងទេថា គេផលិតវាដោយរបៀបណា?" សូមឲ្យសិស្សផ្តល់ចម្លើយរបស់ខ្លួន។

៥. សង្ខេបសកម្មភាព ដោយបញ្ជាក់ប្រភេទអំណះអំណាងជាមួយសិស្ស ដូចខាងក្រោម "ឈ្មោះកន្លែងនិងលក្ខណៈសណ្ឋានដី ដែលជារឿយៗមានទំនាក់ទំនងគ្នា ដូចដែលរឿងព្រេង និងរឿងនិទានក៏មានទំនាក់ទំនង ជាមួយបាតុភូតធម្មជាតិ ដែលបានឃើញនៅក្នុងតំបន់មួយផងដែរ"។ បញ្ហាបរិស្ថានកំពុងតែកើតមានឡើង នៅទីកន្លែងដែលអ្នកកំពុងរស់នៅសាំជាមួយ។

សកម្មភាពទី ២) បទសម្ភាស៍ និងលំដាប់ពេលវេលាសម្រាប់ពេលអនាគត (ត្រូវការរយៈពេល៖ ប្រហែល ៤០នាទី

១. ឲ្យសិស្សសួរមនុស្សធំពេញវ័យ ដែលគេស្គាល់ថា តើបរិស្ថានធម្មជាតិនៅក្នុងភូមិរបស់គេជាពិសេសព្រៃឈើ បឹង និងទន្លេ មានការប្រែប្រួលយ៉ាងណានៅអំឡុងពេល ១០ ឬ ២០ឆ្នាំចុងក្រោយនេះ ហើយសង្ខេបការយល់ឃើញរបស់ខ្លួន។ ជាពិសេស ប្រសិនបើកន្លែងណាមួយនៅក្បែរភូមិនោះមានផលិតអំបិលឲ្យសិស្សធ្វើការស្រាវជ្រាវអំពី បម្រែបម្រួលបរិស្ថានណាមួយ ដែលបានកើតឡើងនៅក្នុងតំបន់នោះ។

២. អនុវត្តជំហានទី ១ ដល់ទី ៤ ពីសកម្មភាពទី ១)

៣. ប្រាប់សិស្សថា "ចូរគិតអំពីអនាគតនៃកន្លែងផលិតអំបិល ដែលកំពុងត្រូវបានអនុវត្ត(ឬព្រៃឈើ បឹង និងទន្លេ)"។ គូរទម្រង់លម្អិតនៃដ្យាក្រាមកំណត់ពេលវេលាសម្រាប់ពេលអនាគត (សូមមើលសកម្មភាពទី ៣) រឿងនិទាន ទីទុយ និងក្តាន់) ជាមួយ "អតីតកាល" នៅខាងឆ្វេង។

៤. នៅលើដ្យាក្រាម ចូរសរសេរអំពី អ្វីដែលបានកើតឡើងតាំងពីអតីតកាល រហូតដល់ពេលបច្ចុប្បន្ន។

៥. សួរសិស្សថា តើរឿងអ្វីខ្លះដែលអាចកើតមានឡើង ដើម្បីសរសេរចូលក្នុងបន្ទាត់ពេលវេលាចាប់ពី "បច្ចុប្បន្ន" ដល់ "អនាគត ខ្ញុំមិនចង់ឃើញ – ធនធាននានាបាត់បង់ឡើយ" ហើយចូរសរសេរចម្លើយទាំងនោះនៅលើដ្យាក្រាម។

៦. បន្ទាប់មក ឲ្យសិស្សផ្តល់គំនិតយោបល់របស់ខ្លួន ថាតើយើងអាចធ្វើអ្វីបានខ្លះ ឬត្រូវមានអ្វីខ្លះកើតឡើង ដើម្បី ឲ្យបន្ទាត់ពេលវេលា "បច្ចុប្បន្ន" ដល់ "អនាគត ខ្ញុំចង់ឃើញ – ធនធានសម្បូរបែប" ហើយសរសេរគំនិតយោបល់ទាំងនោះនៅលើដ្យាក្រាម។

៧. ពិនិត្យមើលទូទៅលើដ្យាក្រាម ដែលបានបំពេញ ហើយសង្ខេបសកម្មភាព ដោយនិយាយអំពីអ្វីដែលបានកើតឡើង (ចាប់ពីអតីតកាលដល់បច្ចុប្បន្ន) នាំឲ្យមានស្ថានភាពដូចពេលបច្ចុប្បន្ន និងអ្វីដែលយើងត្រូវតែធ្វើ ឬ អ្វីដែលយើងចាំបាច់ត្រូវសម្រេចឲ្យបាន ដើម្បីនាំមកនូវអនាគតដែលពោរពេញទៅដោយធនធានសម្បូរបែបនៅក្នុងភូមិ ឬក្នុងតំបន់នេះ។

## សារជូនចំពោះអ្នកសម្របសម្រួល៖ គោលបំណងនៃសម្ភារៈឧបទេស និងរបៀបប្រើប្រាស់សម្ភារៈទាំងនេះ

កូនសៀវភៅនេះ គឺជាឧបករណ៍មួយ សម្រាប់ជួយដល់សិស្សានុសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ឲ្យចាប់អារម្មណ៍ទៅលើបរិស្ថានធម្មជាតិ ដែលសុំាជាមួយនឹងពួកគេ ហើយគិតអំពីបញ្ហា បរិស្ថាន តាមរយៈការប្រើប្រាស់រឿងនិទាននានា ដែលបានដំណាលតៗគ្នា នៅតាមតំបន់ដងទន្លេមេគង្គ។

យើងមានសង្ឃឹមយ៉ាងមុតមាំថា អ្នកនឹងប្រើប្រាស់រឿងនិទានទាំងនេះ ជាគន្លឹះ ដើម្បីផ្តល់ឱកាសឲ្យកុមារគិតអំពីបរិស្ថាន និងរបៀបរស់នៅតាមមូលដ្ឋាន។

ក្រុមគោលដៅ

ឯកសារនេះ គឺសម្រាប់ប្រើប្រាស់ជាមួយសិស្សានុសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សា(ចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៩)

គោលបំណងឯកសារ (លទ្ធផលសិក្សា ដែលបានរំពឹងទុក)

១. បង្កើនអារម្មណ៍សុំាជាមួយ សត្វ និងរុក្ខជាតិក្នុងស្រុក ព្រមទាំងបណ្តុះគំនិតចង់ថែទាំសត្វ និងរុក្ខជាតិទាំងនោះ។

២. កត់សម្គាល់ និងយល់ដឹងអំពី ការថយចុះនូវចំនួន សត្វ និងរុក្ខជាតិ បើប្រៀបធៀបជាមួយនិងកាលពីសម័យមុន។

៣. កត់សម្គាល់ និងយល់ដឹងអំពី ទំនាក់ទំនងរវាងការពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់មនុស្ស (ការអភិវឌ្ឍ) ភ្ជាប់ជាមួយបម្រែបម្រួលនៃរបៀបរស់នៅ និងបម្រែបម្រួលបរិស្ថានធម្មជាតិ។

៤. ប្រមើលមើល និងចែករំលែកស្ថានភាព ដែលគួរតែមានសម្រាប់ផ្នែកនេះ ព្រមទាំងចក្ខុវិស័យដែលចង់បាននាពេលអនាគតសម្រាប់ផ្នែកនោះ។

៥. ស្គាល់ និងយល់ដឹងអំពីបញ្ហានានា ដែលមានទំនាក់ទនងជាមួយការអភិវឌ្ឍ។

៦. គិតអំពីអ្វីដែលអាចធ្វើបាន និងអ្វីដែលគួរតែធ្វើ ដើម្បីការពារបរិស្ថានធម្មជាតិ។

# នីតិវិធីជាមូលដ្ឋាន




**ចំណុចគន្លឹះ**

- នៅពេលរៀបចំសិក្ខាសាលា ត្រូវរៀបចំទុកជាមុននូវសម្ភារៈ ដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសកម្មភាព (ឧទាហរណ៍៖ ផ្ទាំងក្រដាស ប៊ិចហ្វឺត ស្កុតក្រដាស និងក្រដាស A4 ។ល។ សម្រាប់ការងារក្រុម)។
- នៅពេលធ្វើសិក្ខាសាលា ត្រូវបែងចែកអ្នកចូលរួមជា ៤ក្រុមតូចៗ ហើយក្នុងក្រុមនីមួយៗ ត្រូវមានសមាជិក ៦នាក់។ ស្នើសុំឲ្យក្រុមទាំងនេះពិភាក្សាអំពីបញ្ហា ដែលបានកើតឡើងក្នុងអំឡុងពេលសកម្មភាព និងធ្វើបទបង្ហាញពីលទ្ធផលរបស់ពួកគេ។

គុណតម្លៃ៖ គំនិតនានា ដែលយើងសង្ឃឹមថា អ្នកនឹងសង្កត់ធ្ងន់តាមរយៈការប្រើប្រាស់សម្ភារៈឧបទេសទាំងនេះ

- សារៈសំខាន់គឺសង្កត់ធ្ងន់លើ ការគិត និងពិភាក្សាអំពី ទស្សនៈវប្បធម៌ បរិបទ និងរឿងនិទានដែលជាឬសគល់នៅក្នុងតំបន់មូលដ្ឋាន។
- បរិស្ថានធម្មជាតិគួរតែអភិរក្ស។
- វប្បធម៌ប្រពៃណីដូចជា និទានកថា និងពិធីបុណ្យសាសនា ដែលបានបន្សល់ទុកពីមួយជំនាន់ទៅមួយជំនាន់ នៅក្នុងតំបន់មូលដ្ឋានគួរតែការពារ និងអភិរក្ស។

តើអ្វីជា

## "កិច្ចតែងការបង្រៀនអំពីបរិស្ថាន ដែលប្រើប្រាស់គម្រោង រឿងដំណាលអំពីមនុស្ស"?

នៅក្នុងអាងទន្លេមេគង្គ ដែលទីនេះគឺជាឫសគល់នៃការរស់នៅ និងការចិញ្ចឹមជីវិតរបស់ធនធានធម្មជាតិមាន រឿងព្រេង រឿងនិទាន សុភាសិត និងអ្វីផ្សេងៗជាច្រើនទៀត ដែលជាបណ្តាំនៃ ធនធានធម្មជាតិ មនុស្ស និងសត្វ ត្រូវបានបន្សល់ទុកជាច្រើនជំនាន់មកហើយ។ "រឿងដំណាលអំពីមនុស្ស" ទាំងនេះ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការបញ្ចៀសការប្រើប្រាស់ធនធានធម្មជាតិ ឬទាញយកធនធានធម្មជាតិហួសកម្រិត និងការការពារធម្មជាតិ ដោយអ្នកស្រុក។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ យើងសង្កេតឃើញថា មានការថយចុះនូវធនធានធម្មជាតិ យ៉ាងឆាប់រហ័សក្នុងតំបន់នេះ នៅពេលការអភិវឌ្ឍសេដ្ឋកិច្ចមានសន្ទុះកើនឡើង។ អង្គការ **Mekong Watch** បាននឹងកំពុងកត់ត្រា រឿងព្រេង និងរឿងនិទានអំពី ធម្មជាតិ មនុស្ស និងសត្វ ហើយខិតខំប្រឹងប្រែងសម្រេចឲ្យបាននូវការយល់ដឹងកាន់តែស៊ីជម្រៅអំពីគុណតម្លៃ ដែលជាមរតកនៃឧត្តមភាព ក្នុងការប្រើប្រាស់ធនធានធម្មជាតិតាមបែបប្រពៃណីនៅតាមដងទន្លេមេគង្គនៅក្នុងប្រទេសទាំងបីគឺ ប្រទេសថៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងប្រទេស កម្ពុជា។

សូមមើលគេហទំព័ររបស់យើងសម្រាប់រឿងនិទានបន្ថែម៖

http://www.mekongwatch.org/PDF/Booklet_PeopleStory.pdf

កូនសៀវភៅនេះ ត្រូវបានផ្តល់មូលនិធិដោយជំនួយឥតសំណងរបស់ មូលនិធិជប៉ុនសម្រាប់បរិស្ថានសកល។

សេ ចក្តីថ្លៃ ងអំណរគុណ៖ **DEAR.**

រូបភាពដោយ : **Mr.Amarit Mothong**

រចនាដោយ : **Ms.Siriporn Pornsiritived**

បោះពុម្ព ផ្សាយដោយអង្គការ **Mekong Watch (info@mekongwatch.org / http://www.mekong-watch.org)** យើងសូមស្វាគមន៍រាល់ការផ្តល់មតិត្រឡប់របស់អ្នក ចំពោះសកម្មភាព ដែលយើងបានអនុវត្តដោយប្រើប្រាស់កូនសៀវភៅនេះ។ សូមផ្ញើមតិត្រឡប់របស់អ្នកមកកាន់អង្គការ **Mekong Watch** ជាភាសាអង់គ្លេស/ថៃ/ឡាវ ឬជប៉ុន តាមរយៈអាសយដ្ឋានអ៊ីមែល ដូចបានបង្ហាញខាងលើ។

កាលបរិច្ឆេទ៖ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៥

Mekong Watch